# ព្រះរាជក្រម

នស/រកម/០៧០៧/០២២

## យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៧នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ ៖

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចការពារ បេតិកភណ្ឌវប្បធម៌ក្រោមទឹក

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលអនុម័តកាលពីថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០០១ នៅទីក្រុងប៉ារីស ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញាអន្តរជាតិនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.០៧០៧.០១៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
រដ្ឋមន្ត្រីស្តីទី

**ហត្ថលេខា**

**ហ៊ឹម ឆែម**

# អនុសញ្ញា
# ស្តីពី
# កិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក

សន្និសីទកំពូលរបស់អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ ដែលបានប្រជុំនាទីក្រុងប៉ារីស ចាប់ពីថ្ងៃទី ១៥ ខែ តុលា ដល់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០០១ នាសម័យប្រជុំលើកទី៣១ :

ដោយទទួលស្គាល់ ពីសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកក្នុងនាមជាផ្នែកមួយ នៃបេតិកភណ្ឌរបស់មនុស្សជាតិ និងក្នុងនាមជាធាតុផ្សំយ៉ាងសំខាន់ពិសេសរបស់ប្រវត្តិសាស្ត្ររបស់មនុស្ស របស់បណ្តាប្រជាជាតិទាំងឡាយ និងទំនាក់ទំនងទៅវិញទៅមក ដែលទាក់ទងទៅនឹងបេតិកភណ្ឌរួម

**ដោយយល់ឃើញថា** វាជាការចាំបាច់បំផុតក្នុងការការពារ និងថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក ហើយដែលការទទួលខុសត្រូវលើភារកិច្ចនេះធ្លាក់ទៅលើរដ្ឋទាំងអស់

**ដោយពិនិត្យឃើញថា** សាធារណជនកាន់តែមានការចាប់អារម្មណ៍ និងឱ្យតម្លៃខ្ពស់លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក

**ដោយជឿជាក់** ពីសារសំខាន់នៃការសិក្សាស្រាវជ្រាវព័ត៌មាន និងការអប់រំដើម្បីកិច្ចការពារ និងការថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក

**ដោយជឿជាក់ថា** សាធារណជនមានសិទ្ធិទទួលបាននូវផលប្រយោជន៍ខាងការអប់រំ និងការកំសាន្តសប្បាយ ព្រមទាំងការបើកចំហប្រកបដោយការទទួលខុសត្រូវ និងគ្មានការគំរាមកំហែងលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ហើយដែលការអប់រំសាធារណជនបានរួមចំណែកក្នុងការធ្វើឱ្យការវាយតម្លៃ ការការពារ និងការយល់ដឹងពីបេតិកភណ្ឌប្រភេទនេះកាន់តែប្រសើរឡើង

**ដោយយល់ឃើញថា** រាល់អន្តរាគមន៍ទាំងឡាយណា ដែលគ្មានការអនុញ្ញាត ឱ្យប្រព្រឹត្តទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក គឺជាការគំរាមកំហែងមួយចំពោះបេតិកភណ្ឌប្រភេទនេះ ហើយដែលចាំបាច់ត្រូវចាត់វិធានការម៉ឺងម៉ាត់ជាងនេះ ដើម្បីរារាំងអន្តរាគមន៍បែបនេះ

**ដោយយល់ច្បាស់ពី** ការចាំបាច់ក្នុងការបង្ការនូវផលប៉ះពាល់ជាអវិជ្ជមាន នៃសកម្មភាពស្របច្បាប់ជាយថាហេតុមួយចំនួន ដែលអាចកើតមានលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក

**ដោយព្រួយបារម្ភយ៉ាងខ្លាំងអំពី** ការកើនឡើង នៃអាជីវកម្មបែបពាណិជ្ជកម្មលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងជាពិសេសសអំពីសកម្មភាពមួយចំនួន ដែលមានគោលបំណងលក់ដូរ ធ្វើលទ្ធកម្ម ឬដោះដូរបំណែកទាំងឡាយនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

ដោយយល់ឃើញ ការអភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យាជួយសម្រួលដល់ការស្រាវជ្រាវ និងរកឃើញនូវបេតិកភណ្ឌវប្បធម៌ក្រោមទឹក

ដោយជឿជាក់ថា កិច្ចសហប្រតិបត្តិការរវាងបណ្តារដ្ឋ បណ្តាអង្គការអន្តរជាតិ ស្ថាប័នវិទ្យាសាស្ត្រ អង្គការវិជ្ជាជីវៈ បុរាណវត្ថុវិទូ អ្នកមុជទឹក ភាគីពាក់ព័ន្ធនឹងមហាជន គឺជាការចាំបាច់បំផុតដើម្បីការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក

ដោយយល់ឃើញថា បុរេសនា[១] កំណាយ និងកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ទាមទារជាចាំបាច់នូវលំហូរចូល និងការពឹងផ្អែកលើវិធីបែបវិទ្យាសាស្ត្រពិសេស និងការប្រើប្រាស់បច្ចេកទេស និងសម្ភារៈសមស្រប ក៏ដូចជាវិជ្ជាជីវៈ ឯកទេសកម្រិតខ្ពស់ដែលគេហៅថា លក្ខណៈវិនិច្ឆ័យឯកភាព

**ដោយយល់ច្បាស់ពីភាពចាំបាច់** ក្នុងការតាក់តែងជាក្រម និងអភិវឌ្ឍនូវវិធានគតិយុត្ត ដែលទាក់ទងទៅនឹងការការពារ និងការថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក ស្របតាមនីតិអន្តរជាតិ និងទំនៀមទម្លាប់អន្តរជាតិ ជាពិសេសអនុសញ្ញារបស់អង្គការយូណេស្កូ ពាក់ពន្ធ័នឹងវិធានការដែលត្រូវប្រកាន់យក សំដៅហាមឃាត់ និងទប់ស្កាត់ការនាំចូល ការនាំចេញ និងការផ្ទេរកម្មសិទ្ធិខុសច្បាប់ នៃសម្បត្តិវប្បធម៌ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧០ នៃអនុសញ្ញារបស់អង្គការយូណេស្កូសម្រាប់ការការពារបេតិកភណ្ឌពិភពលោក បេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ១៩៧២ និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨២

**ដោយព្រួយបារម្ភ** ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃវិធានការ ដែលត្រូវប្រកាន់យកក្នុងកម្រិតអន្តរជាតិ តំបន់ និងជាតិ ដើម្បីថែរក្សាផ្នែកទាំងឡាយនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ក្នុងគោលដៅវិទ្យាសាស្ត្រ ឬការការពារ ដើម្បីប្រមូលយកមកវិញ នូវបេតិកភណ្ឌទាំងនោះ

**ក្រោយពីធ្វើការសម្រេច** ក្នុងសម័យប្រជុំលើកទីម្ភៃប្រាំបួនរបស់ខ្លួន បញ្ហានេះនឹងក្លាយជាកម្មវត្ថុ នៃអនុសញ្ញាអន្តរជាតិមួយ អនុញ្ញានេះទទួលបានការអនុម័ត នៅថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០១ ។

**មាត្រា ១.- និយមន័យ**

ក្នុងន័យនៃអនុសញ្ញានេះ មានពាក្យសព្ទមួយចំនួនដូចខាងក្រោម :

១ (ក) បេតិកភណ្ឌវប្បធម៌ក្រោមទឹកសំដៅដល់ រាល់ដានស្នាមនៃអត្ថិភាពរបស់មនុស្ស ដែលមានចរិតលក្ខណៈវប្បធម៌ប្រវត្តិសាស្ត្រ ឬបុរាណវត្ថុវិទ្យាដែលលិចក្នុងទឹកមួយផ្នែក ឬទាំងស្រុង តាមកាលកំណត់ទៀងទាត់

[១] Prospection : ការរកអណ្តូងរ៉ែ

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិក្រមសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

ឬជាអចិន្ត្រៃយ៍តាំងពីរយៈពេលមួយរយឆ្នាំ(១០០) យ៉ាងតិចមានជាអាទិ៍ :

(ក₁) រមណីយដ្ឋាន រចនាសម្ព័ន្ធ អាគារ វត្ថុ និងសំណល់ឆ្អឹងរបស់មនុស្ស ព្រមទាំងបរិបទបូរាណវត្ថុវិទ្យា និងធម្មជាតិរបស់របស់ទាំងនេះ

(ក₂) នាវា យន្តហោះ យានយន្តដទៃទៀត ឬរាល់ភាគនៃរបស់ទាំងនេះ ដោយមានទាវាំកណ្ណ ឬបន្ទុកដទៃទៀត និងព្រមទាំងបរិបទបុរាណវត្ថុវិទ្យា និងធម្មជាតិ និង

(ក₃) រាល់វត្ថុទាំងឡាយ ដែលមានលក្ខណៈសណ្ឋានជាបុរេប្រវត្តិ ។

(ខ) បំពង់បង្ហូរប្រេង ឧស្ម័ន និងខ្សែកាបួដែលដាក់ ឬដំឡើងក្នុងជម្រៅសមុទ្រ មិនចាត់ទុកជាផ្នែកនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកឡើយ។

(គ) សំណង់ក្រៅពីបំពង់បង្ហូរប្រេង ឧស្ម័ន ឬខ្សែកាបួដែលដាក់ ឬតំឡើងក្នុងជម្រៅសមុទ្រ ហើយដែលកំពុងប្រើប្រាស់នៅឡើយមិនចាត់ទុកជាផ្នែកនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកឡើយ ។

២. (ក) រដ្ឋភាគី សំដៅដល់រដ្ឋទាំងឡាយដែលយល់ព្រមភ្ជាប់ភាតព្វកិច្ចដោយអនុសញ្ញានេះ ហើយដែលអនុសញ្ញានេះចូលជាធរមានចំពោះរដ្ឋទាំងនោះ

(ខ) អនុសញ្ញានេះអនុវត្តចំពោះទឹកដីដែលមានចែងក្នុងមាត្រា ២៦ កថាខណ្ឌទី ២ (ខ) ដែលក្លាយជាភាគីនៃអនុសញ្ញានេះ ស្របតាមលក្ខខណ្ឌដូចបានកំណត់ក្នុងកថាខណ្ឌនេះដែលទាក់ទិនទៅនឹងទឹកដីនីមួយៗ។ ក្នុងន័យនេះ ពាក្យ " រដ្ឋភាគី " សំដៅដល់ទឹកដីទាំងនេះ ។

៣. យូណេស្កូ សំដៅដល់អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ ។

៤. អគ្គនាយក សំដៅដល់អគ្គនាយករបស់អង្គការយូណេស្កូ ។

៥. តំបន់ " ហ្សូន " សំដៅដល់ជម្រៅបាតសមុទ្រ និងស្រទាប់ដីខាងក្រោមរបស់សមុទ្រ ដែលហួសពីដែនកំណត់យុត្តាធិការជាតិ ។

៦. អន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក សំដៅដល់សកម្មភាពមួយដែលមានកម្មវត្ថុជាចម្បងគឺ បេតិកភណ្ឌវប្បធម៌ក្រោមទឹក ហើយដែលអាចប៉ះពាល់ជាខ្លាំងដល់បេតិកភណ្ឌនេះ ឬរាល់សកម្មភាពដែលបណ្តាលឱ្យមានការប៉ះពាល់ ឬការខូចខាតផ្សេងទៀតដោយផ្ទាល់ ឬដោយប្រយោល ។

៧. អន្តរាគមន៍ដែលមានផលវិភាគដោយចៃដន្យចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក សំដៅដល់សកម្មភាពមួយដែលទោះបីមាន ឬគ្មានផលប៉ះពាល់ជាសំខាន់ ឬមួយផ្នែកណាមួយចំពោះកម្មវត្ថុនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកក្តី ក៏អាចប៉ះពាល់ដល់បេតិកភណ្ឌនេះ ឬបង្កឱ្យមានការខូចខាតផ្សេងទៀត ។

៨. នាវា និងយន្តហោះរបស់រដ្ឋ សំដៅដល់នាវាចម្បាំង ឬយន្តហោះដែលជាកម្មសិទ្ធិរបស់រដ្ឋណាមួយ ឬដែលធ្វើប្រតិបត្តិការក្រោមការត្រួតពិនិត្យរបស់រដ្ឋនោះ ប្រើប្រាស់ដោយផ្ទាល់មុខនៅខណៈពេលដែលយន្តហោះ ឬនាវាចម្បាំងទាំងនោះលិច ក្នុងគោលដៅសេវាសាធារណៈ មិនមែនពាណិជ្ជកម្ម ដែលត្រូវបានគេធ្វើអត្តសញ្ញាណកម្មដូចនេះ

ហើយដែលឆ្លើយតបទៅនឹងនិយមន័យនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក។

៩. វិធានទាំងឡាយគឺសំដៅដល់វិធានទាំងឡាយណាពាក់ព័ន្ធទៅនឹងអន្តរាគមន៍ ដែលធ្វើឡើងទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដូចបានរៀបរាប់ក្នុងមាត្រា ៣៣ នៃអនុសញ្ញានេះ ។

## មាត្រា ២.- គោលបំណង និងគោលការណ៍ទូទៅ

១. អនុសញ្ញានេះមានគោលបំណងធានា និងពង្រឹងការការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក។

២. រដ្ឋភាគីទាំងឡាយសហការគ្នាក្នុងកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក។

៣. រដ្ឋភាគីទាំងឡាយថែរក្សាការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដើម្បីជាផលប្រយោជន៍របស់មនុស្សជាតិស្របតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

៤. រដ្ឋភាគីទាំងឡាយចាត់វិធានការជាឯកត្តជន ឬជារួម ស្របតាមអនុសញ្ញានេះ និងស្របតាមនីតិអន្តរជាតិដែលចាំបាច់ ដើម្បីកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដោយប្រើប្រាស់មធ្យោបាយដែលសមស្របបំផុតទៅតាមសមត្ថភាពរៀង១ខ្លួន។

៥. កិច្ចអភិរក្សបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវចាត់ទុកជាជម្រើសអាទិភាពមុនបង្អស់ចំពោះរាល់អន្តរាគមន៍ទាំងឡាយណាមកលើបេតិកភណ្ឌនេះ ដែលមិនទាន់ទទួលបានការអនុញ្ញាត។

៦. ផ្នែកទាំងឡាយនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលរកបានមកវិញត្រូវចាត់វិធានការតម្កល់ទុក រក្សាទុក និងគ្រប់គ្រងយ៉ាងណាដើម្បីធានាកិច្ចអភិរក្សដែលមានលក្ខណៈយូរអង្វែង។

៧. បេតិកភណ្ឌវប្បធម៌ក្រោមទឹកមិនត្រូវប្រើប្រាស់ជាកម្មវត្ថុនៃអាជីវកម្មបែបពាណិជ្ជកម្មណាមួយឡើយ។

៨. ស្របតាមការអនុវត្តត១គ្នានៃរដ្ឋទាំងឡាយ និងស្របតាមនីតិអន្តរជាតិ ជាពិសេសអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ គ្មានបទប្បញ្ញត្តិណាមួយនៃអនុសញ្ញានេះ ដែលអាចត្រូវបានបកស្រាយដូចជាផ្លាស់ប្តូរវិធានទាំងឡាយនៃនីតិអន្តរជាតិ និងការអនុវត្តត១គ្នានៃបណ្តារដ្ឋទាំងឡាយទាក់ទងទៅនឹងអភ័យឯកសិទ្ធិអធិបតេយ្យ ឬសិទ្ធិណាមួយរបស់រដ្ឋណាមួយនោះដែលទាក់ទងទៅនឹងនាវា និងយន្តហោះរបស់រដ្ឋនោះឡើយ។

៩. រដ្ឋភាគីទាំងឡាយធានាថា រាល់សំណល់ឆ្អឹងរបស់មនុស្សទាំងអស់ ដែលលិចក្នុងដែនទឹកសមុទ្រត្រូវបានគោរពយ៉ាងម៉ឺងម៉ាត់។

១០. រដ្ឋគួរលើកទឹកចិត្តឱ្យសាធារណជន មានការចូលរួមប្រកបដោយការទទួលខុសត្រូវ និងមិនមានការភ័យខ្លាចចំពោះការងារបេតិកភណ្ឌវប្បធម៌ក្រោមទឹក តែក្នុងគោលដៅសង្កេតការណ៍ ឬការងារឯកសារប៉ុណ្ណោះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ចំណាប់អារម្មណ៍របស់សាធារណជនចំពោះបេតិកភណ្ឌប្រភេទនេះ ក៏ដូចជាចូលរួមចំណែកក្នុងការលើកតម្លៃនិងការការពារបេតិកភណ្ឌប្រភេទនេះផងដែរ លើកលែងតែក្នុងករណីណា ដែលកិច្ចការនេះមាន

លក្ខណៈវិសមិតភាពជាមួយនឹងមុខងាររបស់គាត់ ។

១១. គ្មានសកម្មភាព ឬអំពើណាមួយដែលធ្វើឡើងលើមូលដ្ឋាននៃអនុសញ្ញានេះ អាចអនុញ្ញាតឱ្យមានសិទ្ធិវាយតម្លៃ សិទ្ធិគាំទ្រ ឬសិទ្ធិប្រឆាំងនឹងការទាមទារអធិបតេយ្យភាព ឬ យុត្តាធិការជាតិឡើយ ។

## មាត្រា៣.- ទំនាក់ទំនងរវាងអនុសញ្ញានេះ និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ

គ្មានបទប្បញ្ញត្តិណាមួយនៃអនុសញ្ញានេះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិយុត្តាធិការ និងករណីយកិច្ចរបស់រដ្ឋទាំងឡាយក្នុងក្របខណ្ឌនៃច្បាប់អន្តរជាតិ រួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ។ អនុសញ្ញានេះត្រូវបកស្រាយ និងអនុវត្តក្នុងបរិបទ និងស្របតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់អន្តរជាតិ រួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ។

## មាត្រា៤.- ទំនាក់ទំនងជាមួយសិទ្ធិទទួលជំនួយ និងសិទ្ធិទទួលផលប្រយោជន៍ពីកំណប់

គ្មានសកម្មភាពណាមួយទាក់ទងទៅនឹងបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលគ្រប់គ្រងដោយអនុសញ្ញានេះចំពោះនឹងសិទ្ធិទទួលជំនួយ និងសិទ្ធិទទួលផលប្រយោជន៍ពីកំណប់ឡើយ លើកលែងតែ :

ក. សកម្មភាពនោះត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ច និង

ខ. សកម្មភាពនោះស្របទាំងស្រុងនឹងអនុសញ្ញានេះ និង

គ. សកម្មភាពនោះធានាថា កិច្ចការពារជាអតិបរមានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ខណៈពេលដែលរាល់ប្រតិបត្តិការនៃការទទួលយកមកវិញត្រូវបានធានា។

## មាត្រា៥.- សកម្មភាពដែលមានឧប្បត្តិហេតុជាយថាហេតុចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក

រដ្ឋជាភាគីនីមួយៗប្រើប្រាស់មធ្យោបាយសមស្របបំផុតដែលខ្លួនមាន ដើម្បីទប់ស្កាត់ ឬកាត់បន្ថយរាល់ផលវិបាកជាអវិជ្ជមាន បណ្តាលមកពីសកម្មភាពទាំងឡាយណា ដែលទាក់ទិនទៅនឹងយុត្តាធិការរបស់ខ្លួន ដែលមានឧប្បត្តិហេតុជាយថាហេតុណាមួយចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក។

មាត្រា៦.- កិច្ចព្រមព្រៀងទ្វេភាគី និងថ្នាក់តំបន់ ឬកិច្ចព្រមព្រៀងពហុភាគី

១. រដ្ឋភាគីទាំងឡាយត្រូវបានលើកទឹកចិត្តឱ្យចុះកិច្ចព្រមព្រៀងទ្វេភាគី និងថ្នាក់តំបន់ ឬកិច្ចព្រមព្រៀងពហុភាគីដទៃទៀត ឬឱ្យកែលម្អកិច្ចព្រមព្រៀងដែលមានស្រាប់ ដើម្បីធានាការថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក។ រាល់កិច្ចព្រមព្រៀងទាំងនេះត្រូវតែស្របជាចំខាតទៅនឹងបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ និងមិនត្រូវធ្វើឱ្យចរិតលក្ខណៈសកលនៃអនុសញ្ញានេះត្រូវចុះខ្សោយឡើយ ។ ក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងទាំងនេះ រដ្ឋទាំងឡាយអាចអនុម័តរាល់វិធាន និងរាល់បទបញ្ជាដែលពាក់ពន្ធ័ផ្ទាល់ សំដៅធានាកិច្ចការពារយ៉ាងប្រសើរបំផុតដល់បេតិកភណ្ឌវប្បធម៌ក្រោមទឹក បើប្រៀបធៀបទៅនឹងបណ្តាវិធានដែលបានអនុម័តក្នុងក្របខណ្ឌនៃអនុសញ្ញានេះ។

២. ភាគីទាំងឡាយនៃកិច្ចព្រមព្រៀងទ្វេភាគី ឬថ្នាក់តំបន់ ឬកិច្ចព្រមព្រៀងពហុភាគីដទៃទៀត អាចអញ្ជើញរដ្ឋទាំងឡាយដែលមានចំណងទាក់ទងពិតប្រាកដ ជាពិសេសចំណងទាក់ទងផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ ឬបុរាណវិទ្យាជាមួយនឹងបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលពាក់ព័ន្ធ ឱ្យចូលរួមក្នុងកិច្ចព្រមព្រៀងទាំងនេះបាន ។

៣. អនុសញ្ញានេះមិនផ្លាស់ប្តូរសិទ្ធិ និងកាតព្វកិច្ចនៃបណ្តារដ្ឋភាគីចូលរួម ក្នុងន័យនៃកិច្ចការពារនាវាដែលលិចក្នុងទឹកស្របតាមកិច្ចព្រមព្រៀងទ្វេភាគី និងថ្នាក់តំបន់ ឬកិច្ចព្រមព្រៀងពហុភាគីដទៃទៀតដែលចុះរួចហើយ មុនការអនុម័តនៃអនុសញ្ញានេះ ជាពិសេសប្រសិនបើកិច្ចព្រមព្រៀងទាំងនេះស្របតាមកម្មវត្ថុ នៃអនុសញ្ញានេះ។

មាត្រា៧.- បេតិកភណ្ឌវប្បធម៌ក្រោមទឹកក្នុងដែនទឹកផ្ទៃក្នុង ដែនទឹកប្រជុំកោះ និងដែនសមុទ្រ

១. ក្នុងការអនុវត្តអធិបតីភាពរបស់ខ្លួន បណ្តារដ្ឋភាគីមានសិទ្ធិផ្តាច់មុខក្នុងការដាក់បទបញ្ជា និងអនុញ្ញាតរាល់កិច្ចអន្តរាគមន៍នានាលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលស្ថិតក្នុងដែនទឹកផ្ទៃក្នុង ដែនទឹកប្រជុំកោះ និងដែនសមុទ្ររបស់ខ្លួន។

២. ដោយមិនប៉ះពាល់ដល់កិច្ចព្រមព្រៀងអន្តរជាតិ និងវិធានការដទៃទៀតនៃច្បាប់អន្តរជាតិ ដែលកំពុងអនុវត្តដើម្បីកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក រដ្ឋភាគីទាំងឡាយអាចចេញបទប្បញ្ញត្តិក្នុងការអនុវត្តវិធានចំពោះកិច្ចអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលស្ថិតនៅក្នុងដែនទឹកផ្ទៃក្នុង ដែនទឹកប្រជុំកោះ និងដែនសមុទ្ររបស់ខ្លួន។

៣. ក្នុងដែនទឹកប្រជុំកោះ និងដែនសមុទ្ររបស់ខ្លួន ក្នុងការអនុវត្តអធិបតិភាពរបស់ខ្លួន និងស្របតាមការអនុវត្តទូទៅដែលត្រូវគោរពរវាងរដ្ឋ និងរដ្ឋ ក្នុងកិច្ចសហប្រតិបត្តិការដើម្បីអនុម័តយកវិធីដ៏ប្រសើរបំផុត សំដៅការពារបណ្តានាវា និង យន្តហោះរបស់រដ្ឋ ហើយក្នុងករណីនៃការរុករកឃើញនាវា និងយន្តហោះរបស់រដ្ឋដែលមានអត្តសញ្ញាណច្បាស់លាស់ រដ្ឋភាគីនានាត្រូវតែផ្តល់ព័ត៌មានដល់រដ្ឋម្ចាស់យានជាភាគីនៃអនុសញ្ញានេះ និងរដ្ឋដទៃទៀតដែលមាន

ទំនាក់ទំនងជិតស្និទ្ធនឹងគ្នា ជាពិសេសខាងផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ ឬ បុរាណវិទ្យា ។

**មាត្រា៨.- បេតិកភណ្ឌវប្បធម៌ក្រោមទឹកក្នុងតំបន់តភ្ជាប់**

ដោយមិនប៉ះពាល់ដល់មាត្រា ៩ និងមាត្រា ១០ ក៏ដូចជាក្នុងការអនុវត្តតាមមាត្រា ៣០៣ កថាខណ្ឌទី ២ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ រដ្ឋភាគីទាំងឡាយអាចដាក់បទប្បញ្ញត្តិ និងអនុញ្ញាតរាល់អន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលស្ថិតក្នុងតំបន់តភ្ជាប់របស់ខ្លួន។ ដើម្បីសម្រេចគោលបំណងនេះ បណ្តារដ្ឋភាគីត្រូវដាក់បទប្បញ្ញត្តិដើម្បីអនុវត្តវិធានទាំងនោះ ។

**មាត្រា៩.- សេចក្តីប្រកាស និងសេចក្តីជូនដំណឹងក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងលើខ្ពង់រាបបាតសមុទ្រ**

១. វាជាកាតព្វកិច្ចរបស់រដ្ឋភាគីក្នុងកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹកស្ថិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងលើខ្ពង់រាបបាតសមុទ្រ ស្របតាមអនុសញ្ញានេះ។

**ជាលទ្ធផល :**

(ក) រដ្ឋភាគីមួយនៅពេលណាពលរដ្ឋរបស់ខ្លួនណាម្នាក់ ឬនាវាដែលមានសញ្ជាតិរបស់ខ្លួនរកឃើញ ឬចង់ធ្វើអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលស្ថិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬលើខ្ពង់រាបបាតសមុទ្រ ត្រូវតម្រូវឱ្យពលរដ្ឋនោះ ឬប្រមុខនាវានោះ ប្រកាសដល់ខ្លួន នូវការរកឃើញ ឬកិច្ចអន្តរាគមន៍នោះ

(ខ) ក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬលើខ្ពង់រាបបាតសមុទ្ររបស់រដ្ឋភាគីមួយទៀត :

(ខ$_1$) រដ្ឋភាគីទាំងឡាយត្រូវតម្រូវឱ្យពលរដ្ឋ ឬប្រមុខនាវារបស់ខ្លួន ប្រកាសនូវការរកឃើញ ឬកិច្ចអន្តរាគមន៍នេះដល់ខ្លួនផង និងដល់ភាគីផ្សេងទៀតផង

(ខ$_2$) ឬក្នុងករណីចាំបាច់ណាមួយនោះ រដ្ឋភាគីត្រូវតម្រូវឱ្យពលរដ្ឋ ឬប្រមុខនាវាប្រកាសដល់ខ្លួននូវការរកឃើញ ឬកិច្ចអន្តរាគមន៍នេះ និងត្រូវធ្វើការផ្សព្វផ្សាយព័ត៌មាននេះបញ្ជូនឱ្យបានលឿន និងប្រកបដោយប្រសិទ្ធភាពជូនដល់រដ្ឋភាគីដទៃទៀត។

២. ដោយតម្កល់នូវលិខិតូបករណ៍សម្រាប់សុំសច្ចាប័ន សុំការយល់ព្រម និងការទទួលយក ឬការសុំចូលជាភាគី រដ្ឋភាគីមួយត្រូវបញ្ជាក់អំពីរបៀបដែលខ្លួននឹងបញ្ជូនសេចក្តីប្រកាសទាំងនេះ ដូចមានចែងក្នុងកថាខណ្ឌទី ១ (ខ) នៃមាត្រានេះ។

៣. រដ្ឋភាគីមួយជូនដំណឹងដល់អគ្គនាយកអំពីការរកឃើញ ឬកិច្ចអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលខ្លួនបានទទួល ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ។

៤. អគ្គនាយកចែកចាយរាល់ព័ត៌មានដែលខ្លួនបានទទួលឱ្យដល់រដ្ឋភាគីទាំងអស់ ស្របតាមខ្លឹមសារកថាខណ្ឌទី ៣ នៃមាត្រានេះ ។

៥. គ្រប់រដ្ឋភាគីអាចជូនដំណឹងឱ្យរដ្ឋភាគីណាមួយ ក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬលើខ្ពង់រាបបាតសមុទ្រដែលមានបេតិកភណ្ឌវប្បធម៌ក្រោមទឹក ហើយដែលចង់បានការពិគ្រោះយោបល់ពីរដ្ឋនេះ អំពីរបៀបធានាកិច្ចការពារប្រកបដោយប្រសិទ្ធភាពចំពោះបេតិកភណ្ឌនេះ ។ សេចក្តីប្រកាសនេះត្រូវឈរលើមូលដ្ឋានទំនាក់ទំនងច្បាស់លាស់រវាងទំនាក់ទំនងផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ ឬបុរាណវិទ្យា ជាមួយនឹងបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលពាក់ព័ន្ធ។

មាត្រា១០.- ការការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹកក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងលើខ្ពង់រាបបាតសមុទ្រ

១. ការអនុញ្ញាតសម្រាប់កិច្ចអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬលើខ្ពង់រាបបាតសមុទ្រ អាចប្រព្រឹត្តទៅបាន លុះត្រាតែស្របនឹងបទប្បញ្ញត្តិ នៃមាត្រានេះ។

២. រដ្ឋជាភាគីមួយ ដែលមានបេតិកភណ្ឌវប្បធម៌ក្រោមទឹកស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬលើខ្ពង់រាបបាតសមុទ្ររបស់ខ្លួន មានសិទ្ធិហាមឃាត់ ឬអនុញ្ញាតរាល់កិច្ចអន្តរាគមន៍លើបេតិកភណ្ឌនេះដើម្បីរារាំងរាល់ការធ្វើឱ្យប៉ះពាល់ដល់សិទ្ធិអធិបតេយ្យ ឬប៉ះពាល់ដល់យុត្តាធិការរបស់ខ្លួន ដូចដែលត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិរួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ។

៣. នៅពេលដែលការរុករកបេតិកភណ្ឌវប្បធម៌ក្រោមទឹកត្រូវបានធ្វើឡើង ឬនៅពេលដែលកិច្ចអន្តរាគមន៍មួយត្រូវបានគ្រោងអនុវត្តលើបេតិកភណ្ឌវប្បធម៌ក្រោមទឹកក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬលើខ្ពង់រាបបាតសមុទ្ររបស់រដ្ឋភាគីណាមួយ រដ្ឋភាគីនេះត្រូវ :

(ក) ពិគ្រោះយោបល់ជាមួយរដ្ឋភាគីដទៃទៀត ដែលបានបង្ហាញពីផលប្រយោជន៍របស់ខ្លួន ស្របតាមមាត្រា ៩ កថាខណ្ឌទី៥ ពីរបៀបដ៏ប្រសើរបំផុតដើម្បីការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក

(ខ) សម្របសម្រួលពិគ្រោះយោបល់ ក្នុងឋានៈជារដ្ឋសម្របសម្រួល លើកលែងតែរដ្ឋនេះប្រកាសយ៉ាងជាក់លាក់ថា ខ្លួនមិនមានបំណងនឹងធ្វើយ៉ាងនេះ។ ក្នុងករណីនេះ រដ្ឋភាគីទាំងឡាយដែលបានបង្ហាញពីផលប្រយោជន៍ស្របតាមមាត្រា៩ កថាខណ្ឌទី៥ ត្រូវចាត់តាំងរដ្ឋណាមួយឱ្យបំពេញនាទីជាអ្នកសម្របសម្រួល។

៤. ដោយមិនធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចរបស់រដ្ឋភាគីទាំងអស់ក្នុងកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក តាមរយៈការអនុម័តនូវរាល់វិធានការសមស្របតាមច្បាប់អន្តរជាតិ សំដៅរារាំងរាល់គ្រោះថ្នាក់ភ្លាមៗចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹកជាពិសេសអំពើឆក់ប្លន់ រដ្ឋសម្របសម្រួលអាចចាត់វិធានការសមស្រប និង ឬផ្តល់ការអនុញ្ញាតចាំបាច់ទាំងអស់ ស្របតាមអនុសញ្ញានេះ ហើយក្នុងករណីចាំបាច់អាចចាត់ការមុនរាល់ការពិគ្រោះយោបល់ដើម្បីរារាំងរាល់គ្រោះថ្នាក់ភ្លាមៗចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដោយហេតុផលនៃសកម្មភាពមនុស្ស ឬដោយ

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

ហេតុផលដទៃទៀត ជាពិសេសការឆក់ប្លន់ ។ ក្នុងពេលអនុម័តវិធានការទាំងនេះ រដ្ឋភាគីអាចស្នើសុំជំនួយពីរដ្ឋភាគីដទៃទៀតបាន ។

៥. រដ្ឋសម្របសម្រួល :

(ក) ត្រូវធ្វើឱ្យសម្រេចនូវវិធានការការពារដែលបានព្រមព្រៀងរវាងរដ្ឋទាំងឡាយ ដែលបានចូលរួមក្នុងការពិគ្រោះយោបល់គ្នា រួមទាំងរដ្ឋសម្របសម្រួល លើកលែងតែរដ្ឋទាំងនោះរួមទាំងរដ្ឋសម្របសម្រួលយល់ព្រមឱ្យរដ្ឋភាគីមួយផ្សេងទៀត ជាអ្នកអនុវត្តវិធានការនេះ។

(ខ) ត្រូវផ្តល់ការអនុញ្ញាតទាំងអស់ដែលចាំបាច់ចំពោះវិធានការទាំងឡាយ ដែលបានព្រមព្រៀងស្របតាមបញ្ញត្តិវិធានទាំងនោះ លើកលែងតែបណ្តារដ្ឋដែលចូលរួមក្នុងការពិគ្រោះយោបល់ រួមទាំងរដ្ឋសម្របសម្រួលសម្រេចប្រគល់ឱ្យរដ្ឋភាគីមួយផ្សេងទៀតជាអ្នកផ្តល់ការអនុញ្ញាតនេះ។

(គ) អាចដឹកនាំរាល់ការស្រាវជ្រាវបឋមជាចាំបាច់ចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងផ្តល់រាល់ការអនុញ្ញាតចាំបាច់ ព្រមទាំងបញ្ជូនយ៉ាងប្រញាប់នូវលទ្ធផលនៃការស្រាវជ្រាវនេះ ដល់អគ្គនាយក ហើយអគ្គនាយកត្រូវបញ្ជូនភ្លាមនូវព័ត៌មានទាំងនេះដល់រដ្ឋភាគីទាំងឡាយដទៃទៀត។

៦. ដោយធ្វើការសម្របសម្រួលនូវរាល់មតិយោបល់ ដោយធ្វើការអនុម័តនូវរាល់វិធានការ និងដោយធ្វើការដឹកនាំការស្រាវជ្រាវបឋម និង ឬដោយផ្តល់នូវការអនុញ្ញាតចាំបាច់ទាំងអស់ ស្របតាមមាត្រានេះ រដ្ឋសម្របសម្រួលត្រូវប្រព្រឹត្តក្នុងនាមរដ្ឋភាគីទាំងមូល មិនមែនសម្រាប់ផលប្រយោជន៍របស់ខ្លួននោះឡើយ។ ទង្វើបែបនេះមិនអាចត្រូវបានលើកឡើងដើម្បីទាមទារសិទ្ធិបុរិមា[១] ឬសិទ្ធិយុត្តាធិការណាមួយដែលមិនទទួលស្គាល់ដោយច្បាប់អន្តរជាតិ ជាពិសេសដោយអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រឡើយ។

៧. ក្រោមបទប្បញ្ញត្តិនៃវាក្យខណ្ឌទី ២និងទី ៤ នៃមាត្រានេះ មិនអនុញ្ញាតឱ្យមានកិច្ចអន្តរាគមន៍ណាមួយ ធ្វើឡើងលើនាវា ឬយន្តហោះរបស់រដ្ឋ ដោយគ្មានការយល់ព្រមពីរដ្ឋសាមី និងដោយគ្មានកិច្ចសហប្រតិបត្តិការពីរដ្ឋសម្របសម្រួលឡើយ។

## មាត្រា១១.- ការធ្វើសេចក្តីរាយការណ៍ និងការជូនដំណឹងនៅក្នុងតំបន់

១. ជាបន្ទុករបស់រដ្ឋភាគីទាំងអស់ ត្រូវការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលស្ថិតក្នុងតំបន់ ស្របតាមអនុសញ្ញានេះ និងស្របតាមមាត្រា ១៤៩ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ។ ដោយហេតុនេះ នៅពេលដែលពលរដ្ឋនៃរដ្ឋភាគីមួយ ឬនាវាដោតទង់ជ័យរបស់រដ្ឋនោះរុករកឃើញ ឬមានបំណងចង់ធ្វើអន្តរាគមន៍

---

[១] Droit préférentiel

លើតំបន់ដែលមានបេតិកភណ្ឌវប្បធម៌ក្រោមទឹក រដ្ឋភាគីនោះចាំបាច់ត្រូវតែឱ្យពលរដ្ឋរបស់ខ្លួន ឬប្រមុខនាវា ប្រកាសប្រាប់នូវការរុករកនោះ ឬកិច្ចអន្តរាគមន៍នោះ ។

២. បណ្តារដ្ឋភាគីត្រូវជូនដំណឹងចំពោះអគ្គនាយក និងចំពោះអគ្គលេខាធិការ នៃអាជ្ញាធរអន្តរជាតិទទួលបន្ទុកជំរាលសមុទ្រជ្រៅ១ អំពីការរុករក ឬកិច្ចអន្តរាគមន៍ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលគេបានប្រកាសប្រាប់ ។

៣. អគ្គនាយកត្រូវផ្តល់ព័ត៌មានដល់គ្រប់រដ្ឋភាគីដោយគ្មានកាលកំណត់ នូវរាល់ព័ត៌ដែលខ្លួនបានជូនដំណឹង ។

៤. រដ្ឋភាគីមួយអាចជូនដំណឹងចំពោះអគ្គនាយកដែលត្រូវពិគ្រោះអំពីវិធីការពារប្រកបដោយប្រសិទ្ធភាពចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក ។ សេចក្តីប្រកាសនោះត្រូវធ្វើឡើងលើមូលដ្ឋាននៃទំនាក់ទំនងពិតប្រាកដមួយជាមួយបេតិកភណ្ឌវប្បធម៌ក្រោមទឹកនេះ ដោយគិតគូរជាពិសេសដល់សិទ្ធិបុរិមាទាំងឡាយនៃបណ្តារដ្ឋដែលមានប្រភពដើមខាងវប្បធម៌ ប្រវត្តិសាស្ត្រ ឬបុរាណវិទ្យា ។

## មាត្រា១២.- កិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹកក្នុងតំបន់

១. លិខិតអនុញ្ញាតអាចត្រូវផ្តល់ឱ្យសម្រាប់កិច្ចអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ស្ថិតនៅក្នុងតំបន់លុះត្រាណាតែខ្លឹមសារនៃលិខិតអនុញ្ញាតនោះស្របតាមបទប្បញ្ញត្តិនៃមាត្រានេះប៉ុណ្ណោះ ។

២. អគ្គនាយកត្រូវអញ្ជើញរដ្ឋភាគីទាំងអស់ដែលបានបង្ហាញពីផលប្រយោជន៍របស់គេ ដូចមានចែងក្នុងមាត្រា ១១ វាក្យខណ្ឌទី ៤ ឱ្យធ្វើការពិគ្រោះយ៉ាងយកចិត្តទុកដាក់អំពីការរក្សាការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ហើយត្រូវជ្រើសតាំងរដ្ឋភាគីមួយ ដែលនឹងទទួលបន្ទុកធ្វើការសម្របសម្រួលពិគ្រោះយោបល់ក្នុងនាមជារដ្ឋសម្របសម្រួល ។ អគ្គនាយកក៏ត្រូវអញ្ជើញអាជ្ញាធរអន្តរជាតិទទួលបន្ទុកជំរាលសមុទ្រជ្រៅ ១ ឱ្យចូលរួមក្នុងការពិគ្រោះយោបល់នោះផងដែរ ។

៣. គ្រប់រដ្ឋភាគីអាចចាត់រាល់វិធានការទាន់ពេល ស្របតាមអនុសញ្ញានេះ ប្រសិនបើចាំបាច់ត្រូវពិគ្រោះយោបល់ជាមុនដើម្បីទប់ស្កាត់រាល់គ្រោះថ្នាក់ជាបន្ទាន់ចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលបណ្តាលមកពីសកម្មភាពរបស់មនុស្សឬសកម្មភាពផ្សេងៗទៀត ដូចជាការលួចប្លន់ជាដើម ។

៤. រដ្ឋសម្របសម្រួល :

(ក) ត្រូវធ្វើឱ្យសម្រេចនូវរាល់វិធានការការពារដែលបានយល់ព្រមដោយបណ្តារដ្ឋចូលរួមក្នុងកិច្ចពិគ្រោះយោបល់ រួមទាំងរដ្ឋសម្របសម្រួល លើកលែងតែបណ្តារដ្ឋពិគ្រោះយោបល់រួមទាំងរដ្ឋសម្របសម្រួលយល់ស្របឱ្យរដ្ឋភាគីមួយផ្សេងទៀតចាត់វិធានការទាំងនេះ ។

(ខ) ត្រូវចេញលិខិតអនុញ្ញាតចាំបាច់ទាំងអស់ចំពោះរាល់វិធានការដែលបានយល់ព្រមរួចហើយ ស្រប

តាមអនុសញ្ញានេះ លើកលែងតែបណ្តារដ្ឋពិគ្រោះយោបល់ រួមទាំងរដ្ឋសម្របសម្រួលយល់ស្របឱ្យរដ្ឋភាគីមួយផ្សេងទៀតចេញលិខិតអនុញ្ញាតទាំងនេះ ។

៥. រដ្ឋសម្របសម្រួលអាចដឹកនាំរាល់ការសិក្សាស្រាវជ្រាវបឋមដែលចាំបាច់ត្រូវធ្វើ ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងចេញរាល់លិខិតអនុញ្ញាតចាំបាច់សម្រាប់កិច្ចការនេះ ហើយរដ្ឋនេះត្រូវបញ្ជូនជាបន្ទាន់នូវលទ្ធផលទាំងឡាយដល់អគ្គនាយកដែលជាអ្នកមានភារកិច្ចផ្ទេរព័ត៌មានទាំងនេះឱ្យដល់បណ្តារដ្ឋភាគីដទៃទៀត ។

៦. ដោយសម្របសម្រួលរាល់កិច្ចពិគ្រោះយោបល់ ដោយចាត់វិធានការដឹកនាំ ចាត់ចែងការស្រាវជ្រាវទាំងឡាយដែលចាំបាច់ជាបឋម និង ឬដោយចេញលិខិតអនុញ្ញាតទាំងឡាយតាមមាត្រានេះ រដ្ឋសម្របសម្រួលធ្វើកិច្ចការនេះដើម្បីជាផលប្រយោជន៍របស់មនុស្សជាតិទាំងមូលក្នុងនាមរដ្ឋភាគីទាំងអស់ ។ គេត្រូវយកចិត្តទុកដាក់ជាពិសេសដល់សិទ្ធិបុរិមារបស់រដ្ឋទាំងឡាយដែលមានប្រភពដើមផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ ឬបុរាណវិត្ថុវិទ្យាប្រហាក់ប្រហែលនឹងបេតិកភណ្ឌដែលពាក់ព័ន្ធ ។

៧. គ្មានរដ្ឋណាមួយអាចធ្វើអន្តរាគមន៍ ឬអនុញ្ញាតឱ្យធ្វើអន្តរាគមន៍លើនាវា ឬយន្តហោះរបស់រដ្ឋដែលស្ថិតក្នុងតំបន់ ដោយគ្មានការយល់ព្រមពីរដ្ឋម្ចាស់នាវា ឬម្ចាស់យន្តហោះនោះបានឡើយ ។

## មាត្រា១៣.- អភ័យឯកសិទ្ធិអធិបតេយ្យ

នាវាចម្បាំង និងនាវារដ្ឋាភិបាល ឬយន្តហោះយោធាដែលទទួលបាននូវអភ័យឯកសិទ្ធិអធិបតេយ្យកំពុងធ្វើប្រតិបត្តិការក្នុងគោលដៅមិនមែនពាណិជ្ជកម្មក្នុងសកម្មភាពធម្មតានៃប្រតិបត្តិការរបស់ខ្លួន ហើយដែលមិនចូលរួមធ្វើអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក គ្មានកាតព្វកិច្ចត្រូវធ្វើសេចក្តីប្រកាសអំពីការរកឃើញបេតិកភណ្ឌវប្បធម៌ក្រោមទឹក តាមមាត្រា ៩ មាត្រា ១០ មាត្រា ១១ និងមាត្រា ១២ នៃអនុសញ្ញានេះទេ ។ ក៏ប៉ុន្តែ ដោយចាត់វិធានការសមស្រប ដែលមិនធ្វើឱ្យប៉ះពាល់ដល់ប្រតិបត្តិការទាំងឡាយផង ដល់សមត្ថភាពប្រតិបត្តិនៃនាវាចម្បាំង និងនាវារដ្ឋាភិបាល ឬយន្តហោះយោធារបស់ពួកគេ ដែលទទួលបានអភ័យឯកសិទ្ធិអធិបតេយ្យ កំពុងប្រតិបត្តិការក្នុងគោលដៅមិនមែនពាណិជ្ជកម្មផង រដ្ឋភាគីទាំងឡាយ ក្នុងវិធានការសមហេតុផល និងអាចធ្វើទៅបាន ត្រូវធានាថានាវាទាំងនេះបានគោរពតាមបទប្បញ្ញត្តិនានា នៃមាត្រា ៩ មាត្រា ១០ មាត្រា ១១ និងមាត្រា ១២ នៃអនុសញ្ញានេះ ។

## មាត្រា១៤.- ការត្រួតពិនិត្យអំពីការហូរចូលក្នុងដែនដីរបស់ខ្លួន ការធ្វើពាណិជ្ជកម្ម និងការរក្សាទុក

រដ្ឋភាគីទាំងឡាយត្រូវចាត់វិធាននានា ដើម្បីរារាំងការហូរចូលក្នុងដែនដីរបស់ខ្លួន ការធ្វើពាណិជ្ជកម្ម និងការកាន់កាប់បេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលនាំចេញដោយខុសច្បាប់ និង ឬដែលត្រូវគេរើបអូស ពេលដែលការ

រីបនុសនោះវលោភលើបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ។

មាត្រា១៥.- ការមិនប្រើប្រាស់នូវតំបន់នានា ដែលស្ថិតនៅក្រោមយុត្តាធិការរបស់រដ្ឋភាគីទាំងឡាយ

រដ្ឋភាគីទាំងឡាយត្រូវចាត់គ្រប់វិធានការ ដើម្បីហាមឃាត់ការប្រើប្រាស់ទឹកដីរបស់ខ្លួន រួមទាំងកំពង់ផែសមុទ្ររបស់ខ្លួនក៏ដូចជាកោះសិប្បនិម្មិត សំណង់នានា និងរចនាសម្ព័ន្ធដែលស្ថិតក្រោមយុត្តាធិការផ្តាច់មុខ ឬដែលស្ថិតនៅក្រោមការត្រួតត្រាផ្តាច់មុខរបស់ខ្លួន សម្រាប់ធ្វើជាមូលដ្ឋានអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលមិនស្របតាមបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ។

មាត្រា១៦.- វិធានការទាក់ទិននឹងពលរដ្ឋ និងនាវា

រដ្ឋភាគីទាំងឡាយត្រូវចាត់គ្រប់វិធានការសមស្រប ដើម្បីធានាថាពលរដ្ឋរបស់ខ្លួន និងនាវាទាំងឡាយដែលដោតទង់ជាតិរបស់ខ្លួន មិនចូលរួមក្នុងកិច្ចអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលមិនស្របទៅនឹងអនុសញ្ញានេះ ។

មាត្រា១៧.- ទណ្ឌកម្ម

១. រដ្ឋភាគីនីមួយៗត្រូវដាក់ទណ្ឌកម្មចំពោះគ្រប់បទល្មើសផ្ទុយនឹងវិធានការដែលខ្លួនបានដាក់ចេញ ដើម្បីជំរុញឱ្យអនុសញ្ញានេះអនុវត្តបានសម្រេច ។

២. ទណ្ឌកម្មដែលយកមកអនុវត្តចំពោះបទល្មើសនានាត្រូវតែមានលក្ខណៈធ្ងន់ធ្ងរដើម្បីធានាការគោរពអនុសញ្ញានេះ និងដើម្បីបន្ថយការប្រព្រឹត្តបទល្មើស ទោះជានៅទីណាក៏ដោយ ។ ការដាក់ទណ្ឌកម្ម គឺសំដៅទប់ស្កាត់រាល់ការទាញយកប្រយោជន៍របស់ជនល្មើសពីសកម្មភាពខុសច្បាប់របស់ខ្លួន ។

៣. រដ្ឋភាគីទាំងឡាយត្រូវសហការគ្នាដើម្បីធានារាល់ការអនុវត្តទណ្ឌកម្មទាំងនេះ ដោយផ្អែកលើមាត្រានេះ ។

មាត្រា១៨.- ការរឹបអូស និងការប្រើប្រាស់ផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក

១. រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់ ដើម្បីធ្វើការរឹបអូសនៅលើទឹកដីរបស់ខ្លួន នូវផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលបានស្រង់យកដោយមិនស្របទៅនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ ។

២. រាល់រដ្ឋភាគីដែលបានធ្វើការរើបអូសផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដោយអនុវត្តតាមអនុសញ្ញានេះ ត្រូវធ្វើការចុះបញ្ជី និងថែរក្សាផ្នែកនានាទាំងនោះ ហើយត្រូវចាត់វាល់វិធានការសមហេតុផល ដើម្បីធានាភាពគង់វង្សស្ថិតស្ថេរនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកទាំងនោះ ។

៣. រាល់រដ្ឋភាគីដែលបានធ្វើការរើបអូសផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដោយអនុវត្តតាមអនុសញ្ញានេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អគ្គនាយក និងដល់រដ្ឋដទៃទៀតដែលមានទំនាក់ទំនងពិតប្រាកដ ជាពិសេសទំនាក់ទំនងខាងវប្បធម៌ ប្រវត្តិសាស្ត្រ ឬបុរាណវិទ្យាជាមួយបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលមានការពាក់ព័ន្ធ ។

៤. រដ្ឋភាគីដែលបានធ្វើការរើបអូសផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវធានាឱ្យមានការប្រើប្រាស់បានជាប្រយោជន៍ទូទៅ ដោយធ្វើការថ្លឹងថ្លែងអំពីភាពចាំបាច់នៃការថែរក្សា និងការសិក្សាស្រាវជ្រាវអំពីសារសំខាន់នៃការផ្គុំឡើងវិញនូវផ្នែកនានាដែលបែកខ្ចែក អំពីសេចក្តីត្រូវការក្នុងការស្វែងយល់របស់មហាជន អំពីការតាំងពិព័រណ៍ និងការអប់រំ ព្រមទាំងសារប្រយោជន៍របស់រដ្ឋទាំងអស់ដែលមានទំនាក់ទំនងពិតប្រាកដ ជាពិសេសទំនាក់ទំនងផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ ឬបុរាណវត្ថុវិទ្យាជាមួយបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលមានការពាក់ព័ន្ធ។

**មាត្រា១៩.- កិច្ចសហការ និងការចែករំលែកព័ត៌មាន**

១. រដ្ឋភាគីទាំងឡាយត្រូវសហការគ្នា និងត្រៀមខ្លួនក្នុងការជួយគ្នាទៅវិញទៅមក ដើម្បីធានាកិច្ចការពារ និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ក្រោមទឹកក្នុងក្របខ័ណ្ឌនៃអនុសញ្ញានេះ ជាអាទិ៍ទៅពេលដែលអាចធ្វើទៅបាន តាមរយៈការសហការគ្នាក្នុងការរុករក ក្នុងការធ្វើកំណាយ ការរៀបចំឯកសារ ការថែរក្សា និងការលើកតម្លៃចំពោះបេតិកភណ្ឌប្រភេទនេះ ។

២. ល្គឹកណាដែលកម្មវត្ថុនៃអនុសញ្ញានេះអាចអនុញ្ញាតឱ្យបាន រដ្ឋភាគីនីមួយៗត្រូវត្រៀមរំលែកជាមួយបណ្តារដ្ឋភាគីដទៃទៀត នូវរាល់ព័ត៌មានដែលពាក់ព័ន្ធនឹងបេតិកភណ្ឌវប្បធម៌ក្រោមទឹក ។ ជាពិសេសរាល់ព័ត៌មាន ដែលពាក់ព័ន្ធនឹងការរកឃើញផ្នែកនានានៃបេតិកភណ្ឌនេះ ជាអាទិ៍ មានទីតាំងរបស់វា មានផ្នែកនានាដែលត្រូវជីកកកាយបាន ឬរើបអូសបាន វត្ថុល្មើសដែលផ្ទុយនឹងអនុសញ្ញានេះ ឬដែលរំលោភលើបទប្បញ្ញត្តិផ្សេងៗនៃច្បាប់អន្តរជាតិ វិធីសាស្ត្រ និងបច្ចេកទេសវិទ្យាសាស្ត្រដែលសមស្របនឹងការវិវត្តរបស់ច្បាប់ ដែលអាចយកមកអនុវត្តបានចំពោះបេតិកភណ្ឌប្រភេទនេះ ។

៣. រាល់ព័ត៌មានដែលទាក់ទងទៅនឹងការរុករកឃើញ ឬទាក់ទងទៅនឹងទីតាំងនៃផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលត្រូវចែករំលែករវាងរដ្ឋភាគីទាំងឡាយ ឬរវាងអង្គការយូណេស្កូ និងបណ្តារដ្ឋភាគី ត្រូវស្ថិតនៅជាសម្ងាត់ ហើយអាចផ្តល់បានចំពោះតែអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តារដ្ឋភាគី លុះណាតែព័ត៌មាននោះសមស្របទៅនឹងច្បាប់ជាតិរបស់ខ្លួន ហើយល្គឹកណាដែលការផ្សព្វផ្សាយព័ត៌មាននេះអាចមានគ្រោះថ្នាក់ ឬហានិភ័យសម្រាប់

ការថែរក្សានូវផ្នែកនានាដែលពាក់ព័ន្ធនឹងបេតិកភណ្ឌនេះ ។

៤. រដ្ឋភាគីនីមួយៗត្រូវចាត់គ្រប់វិធានការសមរម្យដែលអាចធ្វើទៅបាន រួមទាំងការប្រើនូវមូលដ្ឋានទិន្នន័យអន្តរជាតិសមស្រប ដើម្បីផ្សព្វផ្សាយព័ត៌មានដែលខ្លួនមានស្តីពីផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលត្រូវជីកកកាយបាន ឬរឹបអូសបានដោយរំលោភលើអនុសញ្ញានេះ ឬដោយផ្ទុយនឹងច្បាប់អន្តរជាតិ។

## មាត្រា២០.- ការចាប់អារម្មណ៍របស់មហាជន

រដ្ឋភាគីនីមួយៗត្រូវចាត់រាល់វិធានការសមស្រប ដើម្បីធ្វើឱ្យសាធារណជន មានចំណាប់អារម្មណ៍យល់ដឹងពិត អំពីតម្លៃ និងផលប្រយោជន៍របស់បេតិកភណ្ឌវប្បធម៌ក្រោមទឹក និងអំពីសារសំខាន់នៃកិច្ចការពារ ដែលត្រូវបានចែងដោយអនុសញ្ញានេះ។

## មាត្រា២១.- ការបណ្តុះបណ្តាលផ្នែកបុរាណវត្ថុវិទ្យាក្រោមទឹក

រដ្ឋភាគីទាំងឡាយត្រូវសហការគ្នា ដើម្បីរៀបចំការបណ្តុះបណ្តាលផ្នែកបុរាណវត្ថុវិទ្យាក្រោមទឹក ព្រមទាំងផ្នែកបច្ចេកទេសក្នុងការថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងដើម្បីធ្វើការផ្ទេរបច្ចេកវិទ្យាពាក់ព័ន្ធទៅនឹងបេតិកភណ្ឌនេះ ទៅតាមលក្ខខណ្ឌសមស្រប ។

## មាត្រា២២.- អាជ្ញាធរមានសមត្ថកិច្ច

១. ដើម្បីធានាឱ្យមានការអនុវត្តបានត្រឹមត្រូវនូវអនុសញ្ញានេះ បណ្តារដ្ឋភាគីត្រូវបង្កើតក្រុម ឬអាជ្ញាធរមានសមត្ថកិច្ច ឬពង្រឹងអាជ្ញាធរដែលមានស្រាប់ ដើម្បីធ្វើការបង្កើត ការរក្សាទុក និងការធ្វើបច្ចុប្បន្នភាព នៃបញ្ជីសារពើភណ្ឌបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងដើម្បីធានាប្រកបដោយប្រសិទ្ធភាពនូវកិច្ចការពារ ការថែរក្សា ការលើកតម្លៃ និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ក្រោមទឹក ព្រមទាំងការស្រាវជ្រាវ និងការអប់រំ។

២. រដ្ឋភាគីទាំងឡាយត្រូវផ្តល់ព័ត៌មានដល់អគ្គនាយក នូវឈ្មោះ និងអាសយដ្ឋាន នៃអាជ្ញាធរមានសមត្ថកិច្ចខាងផ្នែកបេតិកភណ្ឌវប្បធម៌ក្រោមទឹក។

## មាត្រា២៣.- សន្និសីទនានានៃបណ្តារដ្ឋភាគី

១. អគ្គនាយកជាអ្នកកោះប្រជុំនៃបណ្តារដ្ឋភាគី ក្នុងឆ្នាំក្រោយពីការចូលជាធរមាននៃអនុសញ្ញានេះ បន្ទាប់មកត្រូវកោះប្រជុំយ៉ាងតិចរៀងរាល់ពីរឆ្នាំម្តង។ អគ្គនាយកត្រូវកោះប្រជុំសន្និសីទវិសាមញ្ញមួយនៃបណ្តារដ្ឋភាគី ប្រសិនបើមានការស្នើសុំពីបណ្តារដ្ឋភាគីភាគច្រើន។

២. សន្និសីទនៃបណ្តារដ្ឋភាគីកំណត់អំពីមុខងារ និងការទទួលខុសត្រូវរបស់ខ្លួន ។

៣. សន្និសីទនៃបណ្តារដ្ឋភាគីអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

៤. សន្និសីទនៃបណ្តារដ្ឋភាគី អាចបង្កើតក្រុមប្រឹក្សាពិគ្រោះយោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសមួយរួមមានសមាសភាពជាអ្នកជំនាញ ដែលបេក្ខភាពរបស់ពួកគេត្រូវបានស្នើឡើងដោយបណ្តារដ្ឋភាគី ដែលត្រូវមានការថ្លឹងថ្លែងអំពីគោលការណ៍បែងចែកដោយសមធម៌ស្របតាមភូមិសាស្ត្រនិងស្របតាមកម្មវត្ថុនៃគោលការណ៍តុល្យភាពរវាងភេទនិងភេទ ។

៥. ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាពិគ្រោះយោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសត្រូវជួយរៀបចំសន្និសីទនៃបណ្តារដ្ឋភាគីខាងផ្នែកវិទ្យាសាស្ត្រ ឬបច្ចេកទេស ដែលទាក់ទិនទៅនឹងការអនុវត្តវិធាននានា ។

## មាត្រា២៤.- លេខាធិការដ្ឋាននៃអនុសញ្ញានេះ

១. អគ្គនាយកជាអ្នកទទួលខុសត្រូវចំពោះលេខាធិការដ្ឋាននៃអនុសញ្ញានេះ។

២. មុខងាររបស់លេខាធិការដ្ឋាននេះរួមមានជាអាទិ៍ :

(ក) ការរៀបចំសន្និសីទនៃបណ្តារដ្ឋភាគី ដូចដែលមានចែងក្នុងមាត្រា២៣ កថាខណ្ឌ ទី១

(ខ) ផ្តល់ការឧបត្ថម្ភជាចាំបាច់ដល់បណ្តារដ្ឋភាគិ ដើម្បីអនុវត្តបាននូវរាល់សេចក្តីសម្រេចនានារបស់សន្និសីទនៃបណ្តារដ្ឋភាគី។

## មាត្រា២៥.- ការដោះស្រាយជំម្លោះដោយសន្តិវិធី

១. រាល់ជំម្លោះរវាងរដ្ឋភាគីពីរ ឬច្រើនស្តីពីការបកស្រាយ ឬការអនុវត្តនូវអនុសញ្ញានេះ គឺជាកម្មវត្ថុ នៃកិច្ចចរចា ប្រកបដោយសុទ្ធចិត្ត ឬដោយមធ្យោបាយនៃដំណោះស្រាយសន្តិវិធីតាមជម្រើសរបស់ខ្លួន។

២. ប្រសិនបើការចរចាទាំងនេះមិនអនុញ្ញាតឱ្យមានការដោះស្រាយជម្លោះក្នុងរយៈពេលមួយសមស្រប ជម្លោះនេះអាចដាក់ជូនអង្គការយូណេស្កូជាអ្នកសម្របសម្រួល ដោយការព្រមព្រៀងរួមគ្នារវាងរដ្ឋភាគីនានាដែលពាក់ព័ន្ធ។

៣. ប្រសិនបើគ្មានការសម្របសម្រួលណាមួយអាចកើតឡើងទេ ឬប្រសិនបើការសម្របសម្រួលនោះមិនឈានដល់ដំណោះស្រាយមួយទេ រាល់បទប្បញ្ញត្តិដែលទាក់ទិនទៅនឹងដំណោះស្រាយជម្លោះ ដូចមានចែងក្នុងផ្នែកទី១៥ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ នឹងត្រូវបានយកមកអនុវត្តចំពោះគ្រប់ជម្លោះរវាងបណ្តារដ្ឋភាគីនៃអនុសញ្ញានេះ តាមរយៈការបកស្រាយ ឬការអនុវត្តនៃអនុសញ្ញានេះ ទោះបីរដ្ឋនោះជាភាគី ឬមិនមែនជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រក៏ដោយ ។

៤. គ្រប់នីតិវិធីជ្រើសរើសដោយរដ្ឋភាគីមួយនៃអនុសញ្ញានេះ និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រដូចមានចែងក្នុងមាត្រា២៨៧ ត្រូវបានយកមកអនុវត្តចំពោះដំណោះស្រាយនៃជម្លោះតាមមាត្រានេះ លើកលែងតែរដ្ឋភាគីនេះ ពេលផ្តល់សច្ចាប័ន ទទួលយក ឬយល់ព្រមចូលជាសមាជិកនៃអនុសញ្ញានេះ ឬនៅពេលណាមួយបន្ទាប់មក បានជ្រើសរើសយកនីតិវិធីមួយផ្សេងទៀតតាមមាត្រា២៨៧ សម្រាប់ដោះស្រាយជម្លោះដែលកើតចេញពីអនុសញ្ញានេះ។

៥. នៅពេលដែលខ្លួនផ្តល់សច្ចាប័ន ទទួលយក ឬយល់ព្រម ឬចូលជាសមាជិកនៃអនុសញ្ញានេះ ឬនៅពេលណាមួយបន្ទាប់មក រដ្ឋភាគីនៃអនុសញ្ញានេះដែលមិនមែនជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ មានសេរីភាពក្នុងការជ្រើសរើស តាមការប្រកាសជាលាយលក្ខណ៍អក្សរនូវមធ្យោបាយមួយ ឬច្រើនដូចមានចែងក្នុង មាត្រា២៨៧ កថាខណ្ឌទី១ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រសម្រាប់ដោះស្រាយជម្លោះតាមមាត្រានេះ ។ មាត្រា២៨៧ អនុវត្តចំពោះសេចក្តីប្រកាសនេះ ក៏ដូចជាចំពោះគ្រប់ជម្លោះ ដែលរដ្ឋនេះជាភាគី ហើយដែលមិនបានចែងកំណត់ដោយសេចក្តីប្រកាសមួយជាធរមាន ។ ក្នុងគោលបំណងធ្វើការផ្សះផ្សា និងធ្វើជាអាជ្ញាកណ្តាលស្របតាមឧបសម្ព័ន្ធទី៥ និងទី ៧ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ រដ្ឋនេះមានសម្បទាគ្រប់គ្រាន់ក្នុងការចាត់តាំងអ្នកសម្របសម្រួល និងអ្នកអាជ្ញាកណ្តាល ដែលនឹងត្រូវចុះឈ្មោះក្នុងបញ្ជីរៀបរាប់ នៅឧបសម្ព័ន្ធទី ៥ មាត្រា ២ និងនៅឧបសម្ព័ន្ធទី ៧ មាត្រា២ សម្រាប់ដោះស្រាយជម្លោះនានា ដែលកើតចេញពីអនុសញ្ញានេះ ។

## មាត្រា២៦.- ការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិក

១. អនុសញ្ញានេះ អាចដាក់ឱ្យរដ្ឋជាសមាជិករបស់អង្គការយូណេស្កូ ផ្តល់សច្ចាប័ន ទទួលយក ឬយល់ព្រម ។

២. អនុសញ្ញានេះដាក់ឱ្យចូលជាសមាជិកពីសំណាក់ :

(ក) រដ្ឋមិនមែនជាសមាជិកអង្គការយូណេស្កូ តែជាសមាជិករបស់អង្គការសហប្រជាជាតិ ឬសមាជិករបស់ស្ថាប័នជំនាញពិសេសមួយស្ថិតក្នុងប្រព័ន្ធនៃអង្គការសហប្រជាជាតិ ឬរបស់ភ្នាក់ងារអន្តរជាតិផ្នែកថាមពលបរមាណូ ព្រមទាំងបណ្តារដ្ឋភាគីនៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ និងគ្រប់រដ្ឋផ្សេងទៀតដែលបានអញ្ជើញឱ្យចូលជាសមាជិកដោយសន្និសីទកំពូលរបស់អង្គការយូណេស្កូ ។

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិក្រមសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

(ខ) បណ្តាដែនដីដែលទទួលបាននូវស្វ័យភាពផ្ទៃក្នុងពេញលេញបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិ ប៉ុន្តែមិនទាន់បានទទួលឯករាជភាពពេញលេញ ស្របតាមសេចក្តីសម្រេចលេខ ១៥១៤ (១៥) របស់មហាសន្និបាត ហើយដែលមានសមត្ថកិច្ចលើបញ្ហាទាំងឡាយដែលគ្រប់គ្រងដោយអនុសញ្ញានេះ រួមទាំងសមត្ថកិច្ចចុះសន្ធិសញ្ញាស្តីពីបញ្ហាទាំងនេះ ។

៣. រាល់លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន នៃការទទួលយក នៃការយល់ព្រម ឬនៃការចូលជាសមាជិក ត្រូវតម្កល់ទុកនៅនឹងអគ្គនាយក ។

## មាត្រា២៧.- ការចូលជាធរមាន

អនុសញ្ញានេះចូលជាធរមានបីខែក្រោយកាលបរិច្ឆេទនៃការតម្កល់លិខិតូបករណ៍ទី២០ ដូចដែលមានចែងនៅមាត្រា២៦ ប៉ុន្តែចំពោះតែរដ្ឋ ឬដែនដីចំនួន២០ដែលបានតម្កល់លិខិតូបករណ៍របស់ខ្លួនតែប៉ុណ្ណោះ ។ អនុសញ្ញានេះចូលជាធរមានចំពោះរដ្ឋ ឬដែនដីទាំងអស់រយៈពេលបីខែក្រោយកាលបរិច្ឆេទនៃការតម្កល់ទុកលិខិតូបករណ៍របស់ខ្លួន ។

## មាត្រា២៨.- សេចក្តីប្រកាសទាក់ទងទៅនឹងសាគរទ្វីប

នៅពេលដែលខ្លួនផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬចូលជាសមាជិកនៃអនុសញ្ញានេះ រាល់រដ្ឋភាគីទាំងអស់អាចប្រកាសបានគ្រប់ពេលថាវិធានទាំងឡាយដែលអនុវត្តចំពោះសាគរទ្វីបរបស់ខ្លួន គ្មានលក្ខណៈចរិតជាសមុទ្រឡើយ ។

## មាត្រា២៩.- វិសាលភាពអនុវត្តតាមភូមិសាស្ត្រ

នៅពេលដែលខ្លួនផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬចូលជាសមាជិកនៃអនុសញ្ញានេះ រដ្ឋឬ ដែនដីមួយតាមរយៈសេចក្តីប្រកាសដែលបានតម្កល់ទុកទៅកន្លែងរក្សាឯកសារ អាចចែងថាអនុសញ្ញានេះមិនអាចអនុវត្តចំពោះផ្នែកណាមួយជាកំណត់ ស្ថិតក្នុងដែនដីរបស់ខ្លួន ស្ថិតក្នុងដែនទឹកផ្ទៃក្នុង ដែនទឹកប្រជុំកោះ ឬក្នុងដែនសមុទ្ររបស់ខ្លួន ហើយត្រូវបញ្ជាក់ពីមូលហេតុនៃសេចក្តីប្រកាសនៅក្នុងអនុសញ្ញានេះ ។ ប្រសិនបើអាចធ្វើទៅបាន និងក្នុងរយៈពេលសមស្របបំផុត រដ្ឋព្យាយាមប្រមូលលក្ខខណ្ឌទាំងឡាយ ដែលក្នុងនោះអនុសញ្ញានេះ នឹងអនុវត្តចំពោះតំបន់ពិសេសៗ នានា ដែលមានចែងក្នុងសេចក្តីប្រកាសរបស់ខ្លួន ។ នៅពេលដែលកិច្ចការនេះសម្រេចបាន ពេលនោះរដ្ឋនឹងដកសេចក្តីប្រកាសរបស់ខ្លួនចេញទាំងស្រុង ឬមួយផ្នែក ។

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

មាត្រា៣០.- **សិទ្ធិបម្រុងនានា**

លើកលែងតែមាត្រា ២៩ ចេញ គ្មានសិទ្ធិបម្រុងណាមួយអាចធ្វើទៅបានឡើយចំពោះអនុសញ្ញានេះ ។

មាត្រា៣១.- **វិសោធនកម្ម**

១. រដ្ឋភាគីទាំងអស់ តាមរយៈលិខិតជាលាយលក្ខណ៍អក្សរផ្ញើជូនអគ្គនាយក អាចស្នើសុំធ្វើ វិសោធនកម្មចំពោះអនុសញ្ញានេះ ។ អគ្គនាយកមានភារកិច្ចបញ្ជូនលិខិតនេះទៅដល់បណ្តារដ្ឋភាគីទាំងអស់ ។ ក្នុងរយៈពេល៦ ខែបន្ទាប់ពីកាលបរិច្ឆេទនៃការបញ្ជូនលិខិតនេះ ប្រសិនបើរដ្ឋភាគីចំនួនពាក់កណ្តាលយ៉ាងតិចផ្តល់ចម្លើយជាវិជ្ជមានចំពោះការស្នើសុំនេះ នោះអគ្គនាយកអាចដាក់សេចក្តីស្នើសុំនេះសម្រាប់ពេលសន្និសីទបន្ទាប់នៃបណ្តារដ្ឋភាគីដើម្បីធ្វើការពិភាក្សា និងធ្វើការអនុម័តជាយថាហេតុ ។

២. វិសោធនកម្មទាំងឡាយត្រូវអនុម័តតាមសំឡេងភាគច្រើនពីរភាគបី នៃបណ្តារដ្ឋភាគីវត្តមាននិងចូលរួមបោះឆ្នោត ។

៣. វិសោធនកម្មនៃអនុសញ្ញានេះ នៅពេលដែលបានទទួលការអនុម័តរួចហើយ ត្រូវដាក់ជូនបណ្តារដ្ឋភាគីដើម្បីសុំការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការបញ្ចូលជាសមាជិក ។

៤. សម្រាប់រដ្ឋភាគីទាំងឡាយ ដែលបានផ្តល់សច្ចាប័ន បានទទួលយក បានយល់ព្រម ឬបានចូលជាសមាជិករួចហើយ ការធ្វើវិសោធនកម្មចំពោះអនុសញ្ញានេះចូលជាធរមានរយៈពេលបីខែក្រោយបន្ទាប់ពីបានតម្កល់លិខិតូបករណ៍ទាំងឡាយ ដូចមានចែងនៅវាក្យខណ្ឌទី៣ នៃមាត្រានេះ ដោយបណ្តារដ្ឋភាគីចំនួនពីរភាគបី (២/៣) ។ បន្ទាប់មកសម្រាប់រដ្ឋ ឬដែនដីនីមួយៗដែលផ្តល់សច្ចាប័ន ទទួលយក យល់ព្រមចំពោះវិសោធនកម្ម ឬចូលជាសមាជិក ហើយវិសោធនកម្មនេះចូលជាធរមានរយៈពេលបីខែក្រោយបន្ទាប់ពីកាលបរិច្ឆេទ នៃការតម្កល់ទុកដោយភាគីនេះ នូវលិខិតូបករណ៍ផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬចូលជាសមាជិករបស់ខ្លួន ។

៥. រដ្ឋ ឬដែនដីមួយដែលក្លាយជាភាគីនៃអនុសញ្ញានេះ ក្រោយការចូលជាធរមាននៃវិសោធនកម្មមួយស្របតាមវាក្យខណ្ឌទី៤ នៃមាត្រានេះ ដោយមិនបានបញ្ចេញឆន្ទៈផ្សេងពីនេះត្រូវចាត់ថា :

(ក) ជាភាគីនៃអនុសញ្ញាដែលបានធ្វើវិសោធនកម្មរួចហើយ និង

(ខ) ជាភាគីនៃអនុសញ្ញាដែលមិនបានធ្វើវិសោធនកម្មចំពោះរដ្ឋភាគីទាំងអស់ ដែលមិនត្រូវបានចងភ្ជាប់កាតព្វកិច្ចដោយវិសោធនកម្មនេះ ។

មាត្រា៣២.- **ការប្តឹងបដិសេធន៍**

១. រដ្ឋភាគីមួយអាចធ្វើការប្តឹងបដិសេធន៍អនុសញ្ញានេះបានតាមរយៈបណ្តឹងជាលាយលក្ខណ៍អក្សរផ្ញើជូនអគ្គនាយក ។

២. ការប្តឹងបដិសេធនឹមានអានុភាពដប់ពីរខែក្រោយមក បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង លើកលែងតែពាក្យបណ្តឹងនេះកំណត់កាលបរិច្ឆេទមួយក្រោយទៀត។

៣. ការប្តឹងបដិសេធនឹមិនធ្វើឱ្យប៉ះពាល់អ្វីសោះឡើយដល់ករណីយកិច្ចរបស់គ្រប់រដ្ឋភាគីក្នុងការបំពេញកាតព្វកិច្ចទាំងអស់ ដូចដែលមានចែងក្នុងអនុសញ្ញានេះ ហើយដែលរដ្ឋភាគីទាំងនេះត្រូវគោរពតាមច្បាប់អន្តរជាតិ ដែលមានលក្ខណៈឯករាជ្យពីអនុសញ្ញានេះ។

**មាត្រា៣៣.- វិធាននានា**

បណ្តាវិធានដែលបានចងភ្ជាប់ជាឧបសម្ព័ន្ធនៃអនុសញ្ញានេះគឺជាផ្នែករួមបញ្ចូលនៃអនុសញ្ញានេះ លើកលែងតែមានបទប្បញ្ញត្តិជាក់លាក់ផ្ទុយពីនេះ ការយោងណាមួយទៅនឹងអនុសញ្ញានេះក៏ជាការឆ្លើយតបទៅលើវិធានទាំងនោះដែរ ។

**មាត្រា៣៤.- ការចុះបញ្ជីនៅអង្គការសហប្រជាជាតិ**

ស្របតាមមាត្រា១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ អនុសញ្ញានេះនឹងត្រូវបានចុះបញ្ជីនៅលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ យោងតាមពាក្យសុំរបស់អគ្គនាយក ។

**មាត្រា៣៥.- អត្ថបទផ្លូវការ**

អនុសញ្ញានេះត្រូវបានរៀបចំឡើងជាភាសាអង់គ្លេស អារ៉ាប់ ចិន អេស្ប៉ាញ៉ុល បារាំង និងរុស្ស៊ី អត្ថបទទាំងប្រាំមួយភាសានេះ មានតម្លៃជាផ្លូវការដូចគ្នា។

# ឧបសម្ព័ន្ធ

វិធាននានាទាក់ទិនទៅនឹងអន្តរាគមន៍នានាលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក

## ១.- គោលការណ៍ទូទៅ

វិធាន១: ដើម្បីថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក ការអភិរក្សត្រូវចាត់ទុកដូចជាកិច្ចការអាទិភាព ។ ជាលទ្ធផល រាល់អន្តរាគមន៍ដែលធ្វើទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវបានអនុញ្ញាត លុះណាតែធ្វើសមស្របជាមួយកិច្ចការពារបេតិកភណ្ឌនេះប៉ុណ្ណោះ ហើយអាចអនុញ្ញាតបានតែក្នុងលក្ខខណ្ឌដែលការធ្វើអន្តរាគមន៍ទាំងនេះបានរួមវិភាគទានដ៏មានសារសំខាន់ដល់កិច្ចការពារ ដល់ការយល់ដឹង ឬដល់ការលើកតម្លៃបេតិកភណ្ឌនេះ ។

វិធាន២: ការធ្វើអាជីវកម្មខាងពាណិជ្ជកម្មលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ក្នុងគោលដៅជំនួញ ឬកេងកម្រៃ ឬការធ្វើឱ្យបែកខ្ញែកដែលមិនអាចជួសជុលបាន គឺមានលក្ខណៈវិសមិតភាពទាំងស្រុងទៅនឹងកិច្ចការពារ និងអភិបាលកិច្ចល្អនៃបេតិកភណ្ឌនេះ។ ផ្នែកនានា នៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកមិនអាចធ្វើជាកម្មវត្ថុនៃជំនួញ នៃប្រតិបត្តិការលក់-ទិញ ឬផ្លាស់ប្តូរផ្ទាល់ក្នុងលក្ខណៈជាទំនិញប្រភេទពាណិជ្ជកម្មឡើយ ។

វិធាននេះមិនអាចត្រូវបកស្រាយក្នុងគោលបំណងរាំងខ្ទប់ :

(ក) ការផ្គត់ផ្គង់សេវាបុរាណវត្ថុវិទ្យាវិជ្ជាជីវៈ ឬសេវាពាក់ព័ន្ធចាំបាច់ ដែលប្រភេទ និងគោលបំណង គឺស្របទាំងស្រុងទៅនឹងអនុសញ្ញានេះ ក្នុងលក្ខខណ្ឌដែលមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

(ខ) ឃ្លាំងរក្សាវត្ថុនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលប្រមូលបានក្នុងក្របខណ្ឌនៃគម្រោងស្រាវជ្រាវ ដែលធ្វើឡើងស្របតាមអនុសញ្ញានេះ ល្គឹកណាដែលការរក្សាទុកនេះមិនប៉ះពាល់ដល់សារប្រយោជន៍ផ្នែកវិទ្យាសាស្ត្រ ឬវប្បធម៌ឬដល់ភាពដើមនៃផ្នែកនានាដែលប្រមូលបាន មិនបណ្តាលឱ្យមានការបែកបាក់ដែលមិនអាចជួសជុលបាន ទោះជាស្របទៅនឹងបទប្បញ្ញត្តិនៃវិធាន ៣៣ និង៣៤ និងទោះជាត្រូវស្នើសុំការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចក៏ដោយ ។

វិធាន៣: បទអន្តរាគមន៍ទាំងឡាយទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក មិនបានធ្វើឱ្យប្រែប្រួលដល់បេតិកភណ្ឌនេះឡើយ ទោះជាវាមានសារសំខាន់ដើម្បីឈានទៅសម្រេចគោលបំណងនៃគម្រោងនេះក៏ដោយ ។

វិធាន៤: បទអន្តរាគមន៍ទាំងឡាយទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវតែប្រើឱ្យមានបច្ចេកទេស និងការរុករកដែលមិនមានការបំផ្លិចបំផ្លាញ ចំពោះការប្រមូលយកវត្ថុទាំងឡាយ ។ ប្រសិនបើការធ្វើកំណាយ ឬការប្រមូលយកបង្ហាញថាមានសារសំខាន់ចំពោះគោលដៅនៃការសិក្សាវិទ្យាសាស្ត្រ ឬចំពោះកិច្ចការពារជាស្ថាពរ នៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក វិធីសាស្ត្រនិង បច្ចេកទេសទាំងនោះ ដែលយកមកប្រើប្រាស់ត្រូវតែមានកម្រិតបំផ្លិចបំផ្លាញយ៉ាងតិចតួចបំផុត និងត្រូវតែបង្កលក្ខណៈងាយស្រួលចំពោះការថែរក្សាការពារដំណោលទាំងឡាយនេះ។

វិធាន៥: បទអន្តរាគមន៍ទាំងឡាយទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក មិនត្រូវធ្វើឱ្យប្រែប្រួល ដោយឥតប្រយោជន៍ដល់សំណល់ឆ្អឹងរបស់មនុស្ស និងកន្លែងពិសិដ្ឋនានាឡើយ។

វិធាន៦: បទអន្តរាគមន៍ទាំងឡាយទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវតែបញ្ញត្តិយ៉ាងតឹងរ៉ឹង ដើម្បីធ្វើឱ្យព័ត៌មានផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ និងបុរាណវត្ថុវិទ្យា ដែលប្រមូលបាន អាចចុះបញ្ជីបានត្រឹមត្រូវ ។

វិធាន៧: រាល់បំណងស្វែងយល់របស់សាធារណជនចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវតែសម្រួលជូន លើកលែងតែក្នុងករណីដែលបំណងស្វែងយល់នេះមានវិសមិតភាពជាមួយកិច្ចការពារ និងការគ្រប់គ្រងនៃរមណីយដ្ឋាននោះ។

វិធាន៨: កិច្ចសហប្រតិបត្តិការអន្តរជាតិផ្នែកអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវតែទទួលបានការលើកទឹកចិត្ត ដើម្បីសម្រួលដល់ការផ្លាស់ប្តូរប្រកបដោយផ្លែផ្កា រវាងបុរាណវិទូនិងអ្នកឯកទេសវិជ្ជាជីវៈដទៃទៀត ដែលមានការពាក់ព័ន្ធ និងដើម្បីប្រើប្រាស់ឱ្យបានប្រសើរបំផុតនូវសមត្ថកិច្ចរបស់ពួកគេ។

## ២.- ពិពណ៌នាអំពីគម្រោង

វិធាន៩: មុនកិច្ចអន្តរាគមន៍ទាំងអស់ ការពិពណ៌នាអំពីគម្រោងត្រូវបានគាក់តែងឡើង និងដាក់ជូនពិនិត្យ ដើម្បីសុំការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ដែលជាអ្នកទទួលរាល់ព័ត៌មានវិទ្យាសាស្ត្រចាំបាច់នានា ។

វិធាន១០: ការពិពណ៌នាគម្រោងរួមមាន:

(ក) តុល្យការនៃការសិក្សាបឋម ឬដំបូង

(ខ) សេចក្តីប្រកាស និងគោលបំណងនៃគម្រោង

(គ) វិធី និងបច្ចេកទេសដែលនឹងប្រើប្រាស់

(ឃ) ផែនការហិរញ្ញប្បទាន

(ង) ប្រតិទិនគ្រោងទុកនៃការប្រតិបត្តិគម្រោង

(ច) សមាសភាពនៃក្រុមទទួលខុសត្រូវគម្រោង ដោយមានការបញ្ជាក់ពីលក្ខណសម្បត្តិ, មុខងារ និងបទពិសោធន៍របស់សមាជិកក្រុមនីមួយៗ

(ឆ) កម្មវិធីវិភាគ និងកម្មវិធីការងារដទៃទៀត ត្រូវប្រគាន់យកបន្ទាប់ពីសកម្មភាពនៅការដ្ឋាន

(ជ) កម្មវិធីអភិរក្សសម្ភារៈបុរាណវត្ថុវិទ្យា និងរមណីយដ្ឋាន ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ច

(ឈ) គោលនយោបាយគ្រប់គ្រង និងថែទាំរមណីយដ្ឋានសម្រាប់ពេញមួយរយៈពេល នៃគម្រោងមួយ

(ញ) កម្មវិធីរក្សាឯកសារ

(ដ) ផែនការសន្តិសុខ

(ឋ) នយោបាយបរិស្ថាន

(ឌ) របៀបបទសហការជាមួយសារមន្ទីរ និងស្ថាប័នដទៃទៀតជាពិសេសផ្នែកវិទ្យាសាស្ត្រ

(ឍ) ផែនការរៀបចំរបាយការណ៍

(ណ) របៀបបទនៃការរក្សាទុកបណ្ណសារកំណាយ រួមទាំងផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលប្រមូលបាន និង

(ត) កម្មវិធីផ្សព្វផ្សាយ ។

**វិធាន១១:** រាល់កិច្ចអន្តរាគមន៍ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវដំណើរការឱ្យស្របតាមការពិពណ៌នាគម្រោងដែលយល់ព្រមដោយអាជ្ញាធរមានសមត្ថកិច្ច។

**វិធាន១២:** ក្នុងករណីនៃការរកឃើញដោយមិនបានគ្រោងទុក ឬក្នុងករណីនៃការផ្លាស់ប្តូរសភាពការណ៍ ការពិពណ៌នាគម្រោង ត្រូវតែពិនិត្យឡើងវិញ និងកែសម្រួល ដោយមានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច។

**វិធាន១៣:** ក្នុងករណីបន្ទាន់ ឬក្នុងករណីនៃការរកឃើញដោយចៃដន្យ រាល់កិច្ចអន្តរាគមន៍ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក រួមទាំងវិធានការអភិរក្សនានា ឬសកម្មភាពរយៈពេលខ្លី ជាពិសេសដើម្បីស្ថេរភាពរមណីយដ្ឋាន និងដើម្បីកិច្ចអន្តរាគមន៍ដើម្បីថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក អាចអនុញ្ញាតឱ្យបាន ទោះបីជាគ្មានបទពិពណ៌នា

គម្រោងក៏ដោយ ។

### ៣.- ការសិក្សាបឋម

**វិធាន១៤:** ការសិក្សាបឋមនានា ដែលមានចែងនៅក្នុងវិធាន១០(ក) រួមមានការវាយតម្លៃអំពីសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក បរិស្ថានធម្មជាតិ និងពីហានិភ័យ ដែលនឹងត្រូវប្រឈមចំពោះការបំផ្លិចបំផ្លាញដោយគម្រោងដែលបានគ្រោងទុក ព្រមទាំងលទ្ធភាពនៃការទទួលបាននូវទិន្នន័យនានា ដែលឆ្លើយតបទៅនឹងកម្មវត្ថុនៃគម្រោង ។

**វិធាន១៥:** ការវាយតម្លៃនេះរួមមានផងដែរនូវការសិក្សាជាមូលដ្ឋានអំពីការវាយតម្លៃបែបប្រវត្តិសាស្ត្រ និងបែបបុរាណវត្ថុវិទ្យា អំពីលក្ខណៈចរិតបែបបុរាណវត្ថុវិទ្យា និងបែបបរិស្ថាននៃរមណីយដ្ឋាន និងអំពីផលវិបាកនៃរាល់ការជ្រៀតចូលជាយថាហេតុចំពោះស្ថេរភាពរយៈពេលវែងនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលពាក់ព័ន្ធដោយកិច្ចអន្តរាគមន៍នានា ។

### ៤.- គោលបំណង វិធីសាស្ត្រ និងបច្ចេកទេសនៃគម្រោង

**វិធាន១៦:** វិធីសាស្ត្រទាំងឡាយដែលប្រើប្រាស់ត្រូវស្របជាមួយនឹងគោលបំណងនៃគម្រោង ហើយបច្ចេកទេសប្រើប្រាស់ក៏ត្រូវមានលក្ខណៈប្រែប្រួលតិចតួចដែលអាចធ្វើទៅបាន ។

### ៥.- ហិរញ្ញប្បទាន

**វិធាន១៧:** លើកលែងតែក្នុងករណីដែលមានការប្រញាប់បន្ទាន់ក្នុងកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ហិរញ្ញប្បទានដ៏សមល្មមមួយត្រូវបានធានាជាមុន មុនពេលចាប់ផ្តើមគ្រប់អន្តរាគមន៍ ក្នុងកម្រិតគ្រប់គ្រាន់មួយដើម្បីដឹកនាំ គ្រប់គ្រងបានល្អគ្រប់ដំណាក់កាលការងារ ដូចដែលបានគ្រោងទុកនៅក្នុងការពិពណ៌នាគម្រោង រួមទាំងការថែរក្សាការរក្សាទុកឯកសារ និងការអភិរក្សសម្ភារៈបុរាណវត្ថុវិទ្យាដែលប្រមូលបាន ព្រមទាំងការរៀបចំតាក់តែង និងការផ្សព្វផ្សាយរបាយការណ៍នានា ។

**វិធាន១៨:** ការពិពណ៌នាគម្រោងត្រូវធានាថាគម្រោងនេះអាចនឹងត្រូវធ្វើហិរញ្ញប្បទានគ្រប់គ្រាន់រហូតដល់

កាលកំណត់នៃលទ្ធផលរបស់វា ដោយទទួលបាននូវការធានារ៉ាប់រងមួយជាឧទាហរណ៍។

វិធាន១៩: ការពិពណ៌នាគម្រោងរួមមានផែនការប្រញាប់បន្ទាន់ ដែលធានាបាននូវការថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងការរក្សាទុកឯកសារដែលមានការពាក់ព័ន្ធ ក្នុងករណីដែលហិរញ្ញប្បទានគ្រោងទុកនោះត្រូវបានកាត់ផ្តាច់។

## ៦.- រយៈពេលនៃគម្រោង - ប្រតិទិនការងារ

វិធាន២០: មុនការចាប់ផ្តើមគ្រប់កិច្ចអន្តរាគមន៍ ប្រតិទិនការងារសមស្របមួយត្រូវបានបង្កើតឡើងដើម្បីធានាផលសម្រេចនូវរាល់ជំហាននានានៃគម្រោង រួមទាំងការថែរក្សា ការរក្សាទុកឯកសារ និងការអភិរក្សផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលប្រមូលមកបាន ព្រមទាំងការរៀបចំតាក់តែង និងការផ្សព្វផ្សាយរបាយការណ៍នានា។

វិធាន២១: ការពិពណ៌នាគម្រោងរួមមានផែនការប្រញាប់បន្ទាន់ដែលធានាការថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងការរក្សាទុកឯកសារដែលជាប់ពាក់ព័ន្ធ ក្នុងករណីដែលគម្រោងនេះនឹងត្រូវកាត់ផ្តាច់ ឬបង្រួញពេល។

## ៧.- សមត្ថភាព និងគុណភាពជំនាញ

វិធាន២២: រាល់អន្តរាគមន៍ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក អាចនឹងធ្វើបានតែក្នុងករណីដែលមានការដឹកនាំ និងការត្រួតពិនិត្យ និងដោយមានវត្តមានជាទៀងទាត់របស់អ្នកឯកទេសដែលមានជំនាញគ្រប់គ្រាន់ផ្នែកបុរាណវត្ថុវិទ្យាក្រោមទឹក នឹងដែលមានសមត្ថភាពផ្នែកវិទ្យាសាស្ត្រស្របតាមប្រភេទនៃគម្រោងនេះ។

វិធាន២៣: គ្រប់សមាជិកទាំងអស់នៃក្រុមដែលទទួលខុសត្រូវគម្រោងត្រូវមានគុណភាពជំនាញ និងមានសមត្ថភាពមួយដែលគេទទួលស្គាល់ ដោយប្រៀបទៅនឹងបេសកកម្មរបស់ពួកគេ។

## ៨.- ការថែរក្សា និងការគ្រប់គ្រងរមណីយដ្ឋាន

វិធាន២៤: កម្មវិធីនៃការថែរក្សាត្រូវបានគ្រោងទុកជាមុននូវវិធីថែទាំដានដំណែលបុរាណវត្ថុវិទ្យា ក្នុងអំឡុង

ពេលនៃកិច្ចអន្តរាគមន៍ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងក្នុងអំឡុងពេលនៃការដឹកជញ្ជូនដានដំណែលបុរាណវត្ថុវិទ្យាសម្រាប់រយៈពេលវែង ។ ការថែរក្សានេះត្រូវធ្វើទៅតាមបទដ្ឋានវិជ្ជាជីវៈនានាដែលនៅជាធរមាន ។

វិធាន២៥: កម្មវិធីនៃការគ្រប់គ្រងរមណីយដ្ឋានត្រូវបានគ្រោងទុកជាមុននូវកិច្ចការពារ និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលកំពុងដំណើរការនៅការដ្ឋាននិងក្នុងកាលកំណត់មួយ ។ កម្មវិធីនេះរួមមានព័ត៌មានរបស់សាធារណជន ការអនុវត្តនូវមធ្យោបាយសមហេតុសមផល ដើម្បីស្ថេរភាពនីយកម្មរមណីយដ្ឋាន ដើម្បីការឃ្លាំមើល និងការការពារ ប្រឆាំងនឹងការជ្រៀតចូលដោយខុសច្បាប់ ។

៩.- ការរក្សាទុកឯកសារ

វិធាន២៦: កម្មវិធីនៃការរក្សាទុកឯកសារ រួមមានការរក្សាទុកឯកសារពិស្តារ នៃរាល់អន្តរាគមន៍ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក រួមទាំងរបាយការណ៍សកម្មភាពមួយដែលឆ្លើយតបទៅនឹងបទដ្ឋានវិជ្ជាជីវៈផ្នែករក្សាទុកឯកសារបុរាណវត្ថុវិទ្យា ដែលនៅជាធរមាន។

វិធាន២៧: ការរក្សាទុកឯកសាររួមមានជាអប្បបរមានូវបញ្ជីសារពើភណ្ឌពិស្តារមួយនៃរមណីយដ្ឋាន រួមទាំងការបញ្ជាក់ពីប្រភពនៃសមាសធាតុបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលបានផ្លាស់ទី ឬបានប្រមូលមក ក្នុងពេលកំពុងអន្តរាគមន៍ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ទៅលើសៀវភៅកំណត់ហេតុរបស់ការដ្ឋាន ប្លង់នានា រូបភាពនានា ឬប្លង់ពុះ ព្រមទាំងរូបថតនានា ឬគ្រប់ឯកសារកត់ត្រាផ្សេងៗទៀត។

១០.- សន្តិសុខ

វិធាន២៨: ផែនការសន្តិសុខមួយពេញលេញត្រូវបានបង្កើតឡើង ដើម្បីធានារ៉ាប់រងសន្តិសុខ និងសុខុមាលភាពរបស់សមាជិកទាំងឡាយ នៃក្រុមដែលទទួលខុសត្រូវគម្រោង និងអ្នកដទៃទៀត ។ ផែនការនេះសមស្របទៅនឹងបញ្ញត្តិច្បាប់ និងវិជ្ជាជីវៈដែលនៅជាធរមាន។

១១.- បរិស្ថាន

វិធាន២៩: គោលនយោបាយបរិស្ថានពេញលេញមួយត្រូវបានរៀបចំតាក់តែងឡើង ដើម្បីរារាំងរាល់ការប៉ះ

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

ពាល់ដោយខុសច្បាប់ដល់ជំរាលសមុទ្រជ្រៅៗ និងជីវសមុទ្រ។

១២.- របាយការណ៍

វិធាន៣០: របាយការណ៍បណ្តោះអាសន្នទាំងឡាយនិងរបាយការណ៍បញ្ចប់មួយ ត្រូវបានរៀបចំឡើងស្របតាមប្រតិទិនការងារដែលមានចែងក្នុងបទពិពណ៌នានៃគម្រោងផែនការ និងត្រូវបានតម្កល់ទុកក្នុងបណ្ណសារដ្ឋានសាធារណៈសមស្រប។

វិធាន៣១: របាយការណ៍នីមួយៗរួមមាន :

(ក) សេចក្តីថ្លែងពីគោលបំណងនានា

(ខ) សេចក្តីថ្លែងពីវិធីសាស្ត្រ និងបច្ចេកទេសដែលប្រើប្រាស់

(គ) សេចក្តីថ្លែងពីលទ្ធផលទទួលបាន

(ឃ) ការរក្សាទុកឯកសារក្រាហ្វិក និងរូបថតសំខាន់ៗដែលមានការពាក់ព័ន្ធទៅនឹងគ្រប់ដំណាក់កាលនៃកិច្ចអន្តរាគមន៍

(ង) អនុសាសន៍នានាពាក់ព័ន្ធទៅនឹងការថែរក្សា និងការអភិរក្សសមាសធាតុនានា នៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលប្រមូលបាន ព្រមទាំងការថែរក្សា និងអភិរក្សរមណីយដ្ឋាន និង

(ច) -អនុសាសន៍នានាពាក់ព័ន្ធទៅនឹងសកម្មភាពអនាគត។

១៣.- ការអភិរក្សបណ្ណសារនៃគម្រោង

វិធាន៣២: បែបបទនៃការអភិរក្សបណ្ណសារនៃគម្រោងត្រូវតែសម្រេចឱ្យបានមុនការចាប់ផ្តើមរាល់កិច្ចអន្តរាគមន៍ទាំងអស់ និងត្រូវបានចែងនៅក្នុងបទពិពណ៌នានៃគម្រោង ។

វិធាន៣៣: បណ្ណសារនៃគម្រោងរួមមានផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលប្រមូលបាន និងគ្រប់ឯកសារថតចម្លងសំខាន់ៗ ។ បើអាចធ្វើទៅបាន ត្រូវរក្សាទុក ដោយមិនបំបែកនិងដោយពេញលេញក្នុងទ្រង់ទ្រាយជាកម្រងសមុច្ច័យ ដើម្បីអនុញ្ញាតឱ្យអ្នកឯកទេសជំនាញនានា និងឱ្យសាធារណជនអាចចូលទស្សនានោះបាន និងដើម្បីធានាកិច្ចអភិរក្សនូវបណ្ណសារទាំងនោះបានសមស្រប ។ ការងារនោះត្រូវសម្រេចឱ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន ហើយយ៉ាងយូរក្នុងរយៈពេលដប់ឆ្នាំបន្ទាប់ពីកាលកំណត់នៃគម្រោងក្នុងវិធានការ នៅពេលណាដែលគម្រោង

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

នោះអនុវត្តស្របទៅនឹងកិច្ចអភិរក្សបេតិកភណ្ឌវប្បធម៌ក្រោមទឹក ។

**វិធាន៣៤:** បណ្ណសារនៃគម្រោងត្រូវគ្រប់គ្រងឱ្យស្របទៅនឹងបទដ្ឋានវិជ្ជាជីវៈអន្តរជាតិ និងក្នុងលក្ខខណ្ឌនៃការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ។

១៤.- ការផ្សព្វផ្សាយ

**វិធាន៣៥:** ក្នុងករណីអាចធ្វើទៅបាន គម្រោងផែនការនេះត្រូវត្រៀមទុកជាមុននូវរាល់សកម្មភាពអប់រំ និងធ្វើការផ្សព្វផ្សាយលទ្ធផលនៃគម្រោងឱ្យបានទូលំទូលាយក្នុងស្រទាប់សាធារណជន ។

**វិធាន៣៦:** សម្រាប់គម្រោងនីមួយៗ របាយការណ៍សំយោគបញ្ចប់ត្រូវ :

(ក) ត្រូវផ្សព្វផ្សាយជាសាធារណៈ តាមដែលអាចធ្វើទៅបាន ដោយគិតទាំងភាពស្មុគស្មាញនៃគម្រោង និងលក្ខណៈសម្ងាត់ ឬរសើបនៃព័ត៌មាន និង

(ខ) តម្កល់ទុកនៅបណ្ណសារដ្ឋានសាធារណៈសមស្រប

អត្ថបទដែលបានរៀបចំឡើងនេះ គឺជាអត្ថបទយថាភូតនៃអនុសញ្ញាដែលត្រូវបានអនុម័តយ៉ាងត្រឹមត្រូវដោយសន្និសីទកំពូលនៃអង្គការយូណេស្កូ នៅសម័យប្រជុំលើកទី៣១ របស់ខ្លួនដែលបានធ្វើឡើងនៅទីក្រុងប៉ារីស ហើយដែលត្រូវបានប្រកាសបិទនៅថ្ងៃទីបី ខែវិច្ឆិកា ឆ្នាំ២០០១ ។

ដើម្បីជាសក្ខីភាព យើងសូមចុះហត្ថលេខានៅថ្ងៃទី៦ ខែ វិច្ឆិកា ឆ្នាំ២០០១។

**ប្រធាននៃសន្និសីទទូទៅ** **អគ្គនាយក**

ច្បាប់ចម្លងបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើមធ្វើនៅទីក្រុងប៉ារីស

**ទីប្រឹក្សាច្បាប់ នៃអង្គការយូណេស្កូ**

ធ្វើនៅទីក្រុងប៉ារីសនាថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០១ ជាពីរច្បាប់យថាភូត ដែលមានហត្ថលេខារបស់ប្រធាននៃសន្និសីទកំពូល ដែលជួបជុំគ្នានៅសម័យប្រជុំទី៣១ របស់ខ្លួន និងហត្ថលេខារបស់អគ្គនាយកអង្គការយូណេស្កូ ដែលអត្ថបទទាំងពីរនេះត្រូវតម្កល់ទុកនៅក្នុងបណ្ណសារដ្ឋាន នៃអង្គការយូណេស្កូ ហើយដែលច្បាប់ចម្លងបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម និងត្រូវប្រគល់ដល់បណ្តារដ្ឋ និងដែនដីទាំងអស់ដែលមានចែងក្នុងមាត្រា ២៦ ព្រមទាំងដល់អង្គការសហប្រជាជាតិ ។

គណៈកម្មការជាតិកម្ពុជាសម្រាប់យូណេស្កូ (CAMNAC
Cambodian National Commission for UNESCO
Commission Nationale du Cambodge pour l'UNESCO

# CONVENTION

# SUR LA PROTECTION DU PATRIMOINE CULTUREL SUBAQUATIQUE

UNESCO

Paris, 2 novembre 2001